ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ៣៧ ត្រីមាសទី០២ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី
ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន
ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៥-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥២៤ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់លោក **គង់ ពុទ្ធីរ៉ា** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងបរិស្ថាន តាមការស្នើសុំរបស់សាមីខ្លួន | ៤៤០៣ |
| ៥-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥២៥ ស្តីពី ការតែងតាំងនិងផ្តល់ឋានៈលោកជំទាវ **លឹម មុយខេង** ជាអនុប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ មានឋានៈស្មើ រដ្ឋលេខាធិការ | ៤៤០៤ |
| ៥-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥២៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ ឯកឧត្តម LAI XUAN CHIEN អគ្គកុងស៊ុល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំខេត្តព្រះសីហនុ | ៤៤០៦ |
| ៥-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥២៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ២២៤អង្គ/រូប | ៤៤០៧ |


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ២០-៤-២០២៦ | -អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ៤៤១២ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៤៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ៤៤៣៩ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៤៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចនិងតែងតាំងមន្ត្រីរាជការ | ៤៤៤១ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ | ៤៤៤៣ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៤៨ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ | ៤៤៤៥ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៤៩ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ | ៤៤៤៧ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥០ អនក្រ.តត ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា | ៤៤៤៩ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៤៥១ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៤៥៣ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៤៥៥ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៤៥៨ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៤៦៧ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៤៧០ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី | ៤៤៨០ |
| ១៧-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៤៨១ |
| ២០-៤-២០២៦ | -អនុក្រឹត្យលេខ ៣៥៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៤៤៨៤ |
| ២០-៤-២០២៦ | -អនុក្រឹត្យលេខ ៣៦០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៤៤៨៩ |

២០-៤-២០២៦ -អនុក្រឹត្យលេខ ៣៦១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៤៩០
២០-៤-២០២៦ -អនុក្រឹត្យលេខ ៣៦២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៤៩៥
២០-៤-២០២៦ -អនុក្រឹត្យលេខ ៣៦៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៤៩៩

**២~សេចក្តីសម្រេច**

២២-៤-២០២៦ -សេចក្តីសម្រេចលេខ ៥០ សសរ ស្តីពី ការចាត់តាំងបន្ថែមអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ ៤៥០២

**III~ការងារបណ្ដាក្រសួង**

**១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

៣១-១២-២០២៥ -ប្រកាសលេខ ១១៦១ សហវ.ប្រក.អរតន ស្តីពី វិធាន និងនីតិវិធីនៃការគ្រប់គ្រងគណនីរបស់និក្ខិត្តកររតនាគារ ៤៥០៤
៥-២-២០២៦ -ប្រកាសអន្តរក្រសួងលេខ ១២៩ សហវ.ប្រក.អរតន ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសប្រចាំនៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា ៤៥១១
៥-២-២០២៦ -ប្រកាសអន្តរក្រសួងលេខ ១៣០ សហវ.ប្រក.អរតន ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទានប្រចាំនៅអង្គភាពថវិកាសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា ៤៥១៥

**២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

២៨-១-២០២៦ -ប្រកាសលេខ ០៥៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ីង លី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងម៉ាស់ ៤៥១៨

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់លោក **គង់ ពុទ្ធីរ៉ា** អត្តលេខ ១៦៨០៥០០០៤៣ នៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងបរិស្ថាន តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពរម. ២៦០៥. ៥៣១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានឃើញថាត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសាស្ត្រាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៧/៣៨៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**ព្រះរាជក្រឹត្យ** — printed header above the decree: **ត្រាស់បង្គាប់**

**មាត្រា១** : តែងតាំងនិងផ្ដល់ឋានៈលោកជំទាវ **លឹម មុយខេង** ជាអនុប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ មានឋានៈស្មើ រដ្ឋលេខាធិការ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣** : សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *០៥* ខែ *ឧសភា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

*ណស. ២៦០៥. ៥៣២*

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**បណ្ឌិតសភាចារ្យ ហ៊ឹង ថូរ៉ាក់ស៊ី**

**ព្រះរាជក្រឹត្យ**

នស/រកត/០៥២៦/៥២៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា**

ចំពោះ

ឯកឧត្តម LAI XUAN CHIEN

អគ្គកុងស៊ុលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំខេត្តព្រះសីហនុ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២៦
**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**
**ប្រមុខរដ្ឋស្តីទី**

តរស. ២៦០៥. ៥៣៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៤៧

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ២២៤អង្គ/រូប៖

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

| | | | |
|---|---|---|---|
| ១- ព្រះកិត្តិធម្មរតន៍ | គ្រិស ស៊ីនួន | ២- ឯកឧត្តម | គង់ ម៉ារីនម៉ូលីវ៉ា |
| ៣- ឯកឧត្តម | ទឹង ឧត្តម | ៤- ឧត្តមសេនីយ៍ត្រី | ជួន វណ្ណថេត |
| ៥- លោកជំទាវ | ស៊ិន ឌីធីតា | ៦- លោកវេជ្ជបណ្ឌិត | វ៉ា សាវុធ |
| ៧- លោក | គង់ ប៊ុនរិទ្ធិ | ៨- លោក | គឿន ភ័ណ្ឌ |
| ៩- លោក | ស៊ុន លី | ១០- លោក | ចាន់ ពលរិទ្ធ |
| ១១- លោក | ប្រាក់ វណ្ណដេត | ១២- លោក | ឈូ ស៊ីវឡាយ |
| ១៣- លោក | សុខ យ៉ាន | | |

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | |
|---|---|---|---|
| ១- ព្រះមហាមុនីពុទ្ធវង្សា | ជឹម សុខលី | ២- ព្រះគ្រូវិជ្ជាសីលឧត្តម | គង់ វុទ្ធី |
| ៣- ឯកឧត្តម | គា អ៊ាវ | ៤- ឯកឧត្តម | ជី ដារ៉ូ |
| ៥- លោក | អូលីវីយេ មីឆែល ម៉ារី ផ្ទឹតហាស្លេ | ៦- ឧបាសក | យឹម យន់ |
| ៧- ឧបាសក | ចេវ បេងទត | ៨- ឧបាសិកា | យើវ មាន |
| ៩- លោក | ទិត្យ ត្បារិទ្ធ | ១០- លោក | ថោង សុខុម |
| ១១- លោក | កង សុវណ្ណ | ១២- លោក | ហេង សំណាង |
| ១៣- លោក | ចន សុខន | ១៤- លោក | អ៊ុនជឿន តារា |
| ១៥- លោក | សុទ្ធ សំ | ១៦- លោក | យ៉ុង យ៉ុន |
| ១៧- លោកស្រី | ស៊ាមរី រង្សី | ១៨- លោក | តាំង អន |
| ១៩- លោកស្រី | ជុំ ស៊ីណាត | ២០- លោក | នីម វ៉ាន់ណៃ |
| ២១- លោក | កប សាមុទ | ២២- លោក | ហេង រតនៈគន្ធា |

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ២៣- លោកស្រី | អៀ បូរីនណេតា | ២៤- លោក | ញ៉ែមករុណា |
| ២៥- លោកស្រី | ហេង គន្ធារិទ្ធី | ២៦- លោកស្រី | ហេង សុផានម៉ៃ |
| ២៧- លោកស្រី | គន ស្រីកែវ | ២៨- លោក | ញ៉ឹម សុកិន |
| ២៩- លោកស្រី | រឿន ស្រួយ | ៣០- វេជ្ជបណ្ឌិត | ហេង វុទ្ធី |
| ៣១- ឱសថការីឧត្តម | ជាង សុគន្ធារី | ៣២- សាស្ត្រាចារ្យ | ថៃ ថាល់ |
| ៣៣- លោក | ផៃ បូរដេត | ៣៤- លោក | វុយ សុវណ្ណយុត្តិ |
| ៣៥- លោក | មាស ពិសិដ្ឋ | ៣៦- លោក | ទូច រដ្ឋា |
| ៣៧- លោក | ឈុំ វង្សដារ៉ែង | ៣៨- លោកស្រី | អ៊ុក សុខមុនី |
| ៣៩- លោក | ប្រាក់ ប៊ុនធឿន | ៤០- លោក | តាំង ហៀង |
| ៤១- លោកទន្តបណ្ឌិត | ប៉ាន់ សុវណ្ណារ៉ា | ៤២- លោក | ជាវ ហ៊ូវ |
| ៤៣- លោក | នាង សុកេន | ៤៤- លោកស្រី | សេន ហ៊ីអូនណា |
| ៤៥- លោក | ឈុន សាមុត | ៤៦- លោក | វង្ស ចំណាន |
| ៤៧- លោក | ជា សុវណ្ណពិទូរ្យ | ៤៨- លោកស្រី | សាវន ស្រីមុំ |
| ៤៩- លោកស្រី | កាន់ ចាន់ថា | ៥០- ឧត្តមសេនីយ៍ត្រី | យុត សុធា |
| ៥១- ឧត្តមសេនីយ៍ត្រី | ម៉ា នាង | ៥២- វរសេនីយ៍ឯក | យី វណ្ណដា |
| ៥៣- វរសេនីយ៍ឯក | អ៊ិន ស្រស់ | ៥៤- វរសេនីយ៍ត្រី | អ៊ីង វុធធឿន |
| ៥៥- វរសេនីយ៍ត្រី | ជិន ជឿន | ៥៦- វរសេនីយ៍ត្រី | លាង រ៉ាវីត |
| ៥៧- វរអគ្គានុរក្សថ្នាក់លេខ២ | ផាត ហួ | ៥៨- វរអគ្គានុរក្សថ្នាក់លេខ៣ | ញ៉ែម សារុន |
| ៥៩- អគ្គានុរក្សថ្នាក់លេខ១ | ខៀវ ប៊ុនណា | ៦០- អគ្គានុរក្សថ្នាក់លេខ១ | ម៉ាច កុសល |
| ៦១- អគ្គានុរក្សថ្នាក់លេខ៣ | ជឿន រតនា | ៦២- អនុសេនីយ៍ឯក | សៀវ សុផេង |
| ៦៣- អនុសេនីយ៍ឯក | ឃួន អ៊ីលីង | ៦៤- អនុសេនីយ៍ឯក | អេង ខេមរិទ្ធិ |
| ៦៥- អនុសេនីយ៍ឯក | ប៉ុង ម៉េងហាក់ | ៦៦- អនុសេនីយ៍ឯក | ឈឿន ម៉ានីន |
| ៦៧- អនុសេនីយ៍ឯក | បូរ សុភាស់ | ៦៨- អនុសេនីយ៍ឯក | ហ៊ុល សំរិន |
| ៦៩- អនុសេនីយ៍ទោ | ថ្លៃ ឈិនឡុង | ៧០- អនុសេនីយ៍ទោ | ហុង ពិសី |
| ៧១- អនុសេនីយ៍ត្រី | ម៉ី សំអាត | ៧២- អនុសេនីយ៍ត្រី | ហាន ឧត្តរ |
| ៧៣- អនុសេនីយ៍ត្រី | អេង អន | ៧៤- អនុសេនីយ៍ត្រី | ភន សុភ័ក្រ |
| ៧៥- អនុសេនីយ៍ត្រី | វង់ សារ | ៧៦- ព្រឹទ្ធបាលទោ | លី សុខលាង |
| ៧៧- ព្រឹទ្ធបាលទោ | លី សុខឡេង | ៧៨- លោកស្រី | សុខ វណ្ណធីតា |
| ៧៩- អនុសេនីយ៍ឯក | យង់ ថាវី | ៨០- អនុសេនីយ៍ឯក | អន សំអឿន |
| ៨១- អនុសេនីយ៍ឯក | ឌី បូរ៉ាស៊ី | ៨២- វរសេនីយ៍ឯក | ចែម វណ្ណៈ |
| ៨៣- អនុសេនីយ៍ត្រី | លី វ៉ាន់នី | ៨៤- លោក | ស្រេង ហុង |
| ៨៥- លោក | ប៊ុត ភារិន | ៨៦- វរសេនីយ៍ត្រី | ញ៉ែម វ៉ាន់ថា |
| ៨៧- អនុសេនីយ៍ឯក | ប៉េង ធីម | ៨៨- លោកស្រី | យឹន សុភាន់ |
| ៨៩- លោក | តាក់ ឆៃ | ៩០- លោក | ម៉ៅ ឧស្សាហ៍ |

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៩១- វរសេនីយ៍ត្រី | ស៊ុ គីមងួន | ៩២- អនុសេនីយ៍ឯក | ជី ច័ន្ទសីហ: |
| ៩៣- អនុសេនីយ៍ឯក | ឃ្លោក ថាវុទ្ធ | ៩៤- អនុសេនីយ៍ទោ | សួរ សុខចិត្រា |

គ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រិយានី ព្រះសីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | |
|---|---|---|---|
| ១- លោក | មាស មេឡាមេលីន | ២- លោក | ទឹម រតនា |
| ៣- លោក | សួន សិទ្ធពោលីន | ៤- លោក | ម៉ែន សុខវុទ្ធីសក្តិ |
| ៥- លោក | លី ជីប៉ | ៦- លោក | ង៉ែន មានិត្យ |
| ៧- វរសេនីយ៍ឯក | ឈួន ច័ន្ទភូនី | ៨- វរសេនីយ៍ទោ | ម៉ៅ ដារីន |
| ៩- វរសេនីយ៍ទោ | ឈួន ច័ន្ទភូនាថ | ១០- វរសេនីយ៍ត្រី | សុខ វីរៈ |
| ១១- វរសេនីយ៍ត្រី | សេង ភារុន | ១២- វរសេនីយ៍ទោ | អាត់ បូណ៌មី |
| ១៣- អនុសេនីយ៍ឯក | លីន ច័ន្ទសុជាត័ន្ទ័ | | |

ឃ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | |
|---|---|---|---|
| ១- លោក | លី ស៊ីនយូ | ២- លោក | ស៊ុះ ជីបព្រេល |
| ៣- លោកស្រី | សាយ បញ្ញា | ៤- លោក | នូ សំណាង |
| ៥- លោក | ថវ មិនាកា | ៦- លោក | លឹម ស្រេងហុង |
| ៧- លោក | វិតឌី មុន្នីវឌ្ឍនៈ | ៨- លោក | ម៉ឹង អ៊ុច |
| ៩- លោក | ឯក សំអុល | ១០- លោក | រតនា វណ្ណារ៉ា |
| ១១- ឧបាសក | ប៉ូវ ណម | ១២- ឧបាសិកា | ឈន ស្រ៊ីម |
| ១៣- ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ | ភួត កណ្ណិកា | ១៤- វរសេនីយ៍ឯក | ពៅ គីមអឹង |
| ១៥- វរសេនីយ៍ឯក | ទិត បូរិន | ១៦- វរសេនីយ៍ត្រី | ប៉ន ចាន់សុភារម្យ |
| ១៧- វរសេនីយ៍ត្រី | ទុន មន្នីវណ្ណ | ១៨- វរសេនីយ៍ត្រី | ទន់ ធារី |
| ១៩- អនុសេនីយ៍ទោ | សុភ័ក្រ ចិត្រា | ២០- អនុសេនីយ៍ទោ | ជិន ស៊ុនហួ |
| ២១- អនុសេនីយ៍ទោ | ជាវ ចាន់ទ្រី | ២២- ព្រឹន្ទបាលទោ | នុត សំរិទ្ធមុនីក្សែ |

ង-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | |
|---|---|---|---|
| ១- ព្រះតេជគុណ | ង៉ែត ចំរើន | ២- ឧបាសក | ម៉ៅ ប៊ុនឡុង |
| ៣- ឧបាសិកា | ជី សុខ | ៤- ឧបាសិកា | វ៉ា សុភី |
| ៥- លោក | ណា ចាន់ភារម្យ | ៦- លោក | ឈឹម សារ៉ែន |
| ៧- លោក | គល់ សំរិត | ៨- លោក | សុត ចន្ថា |
| ៩- ឧត្តមសេនីយ៍ទោ | ស៊ុំ ជាពេញចិត្ត | ១០- វរសេនីយ៍ឯក | ជុំ រចនា |
| ១១- វរសេនីយ៍ឯក | ហុក អេងជាង | ១២- វរសេនីយ៍ទោ | លឹម ឆាំងហួត |
| ១៣- វរសេនីយ៍ទោ | ជិន ចាន់ណា | ១៤- វរសេនីយ៍ត្រី | ឈា ពេជ្ររ័ល្ន័ |
| ១៥- អនុសេនីយ៍ឯក | ប៉ូ ច័ន្ទសំណាង | ១៦- អនុសេនីយ៍ឯក | ស្រេង រិទ្ធី |
| ១៧- អនុសេនីយ៍ឯក | វ៉ាន់ ណារិទ្ធ | ១៨- អនុសេនីយ៍ត្រី | អ៊ុក សុខហៀង |
| ១៩- អនុសេនីយ៍ត្រី | សាត សុខវណ្ណា | ២០- Mr. | NGUYEN HO HAI |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ២១- Ms. | Liu Bing | ២២- Mr. | Gary D.Becks |
| ២៣- Mr. | Alession Vici | ២៤- Mr. | Chen Zhong |
| ២៥- Mr. | Chen Yong Hui | | |

ច-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

| | | | |
|---|---|---|---|
| ១- លោក | ជី វណ្ណា | ២- លោក | ម៉ែន សុខឡេង |
| ៣- លោក | តាំង ស្រ៊ុន | ៤- លោកស្រី | វណ្ណី មករា |
| ៥- វរសេនីយ៍ឯក | ស៊ិន សុខវិបុល | ៦- វរសេនីយ៍ទោ | ប៉ែន វ៉ាលីន |
| ៧- វរសេនីយ៍ទោ | វ៉ន រតនា | ៨- វរអគ្គានុរក្សថ្នាក់លេខ២ | អ៊ុំ សំណាង |
| ៩- អនុសេនីយ៍ឯក | គី ភូជី | ១០- អនុសេនីយ៍ទោ | កែវ មុយហេង |
| ១១- អនុសេនីយ៍ត្រី | ហ៊ិន គិរីរតនៈ | | |

ឆ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា**

| | | | |
|---|---|---|---|
| ១- វរនាវីទោ | គឹម ប៊ុនជៀង | ២- វរសេនីយ៍ត្រី | ហោ ស៊ីភ្លឹង |

ជ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- លោកព្រឹទ្ធាចារ្យ | ម៉ៅ ឆេង | ២- លោកជំទាវ | ហ៊ែល សុផល |
| ៣- លោក | សុខ សុវត្ថិវឌ្ឍនៈ | ៤- លោក | ស សារិន |
| ៥- លោក | យោន ឃាងហ៊ាង | ៦- លោក | សេង ហេងគង់ |
| ៧- លោក | សើ អេះអារី | ៨- លោកស្រី | ស៊ុំ ម៉ូល្លិកា |
| ៩- លោក | ស៊ុំ ឡង់ឌី | ១០- លោក | សំ សីហា |
| ១១- លោក | រឹម ឆាយហួត | ១២- លោក | ឋា ណៃនី |
| ១៣- លោក | គឹង ភាសា | ១៤- លោក | ម៉ែន សុភន |
| ១៥- លោក | អោ សុជា | ១៦- លោក | ទ្រី ពៅ |
| ១៧- លោក | ហេង ខន | ១៨- លោក | វ៉ែន អ៊ិន |
| ១៩- លោក | ជ្រា អេងឈុង | ២០- លោក | ស៊ូ សុផល |
| ២១- លោក | នាង ប៊ុណ្ណា | ២២- លោក | ទេស ធន |
| ២៣- លោក | សុក កុសល់ | ២៤- លោកស្រី | ឈួន ឈាង |
| ២៥- លោកស្រី | សោម កញ្ញា | ២៦- វរសេនីយ៍ទោ | សរ ភារៈ |
| ២៧- វរសេនីយ៍ទោ | រី ភារក្ស | ២៨- វរសេនីយ៍ត្រី | ង៉ែត សុជា |
| ២៩- វរអគ្គានុរក្សថ្នាក់លេខ២ | ម៉ា សុនីពីសី | ៣០- អនុសេនីយ៍ទោ | ស៊ា សុជាតិ |
| ៣១- អនុសេនីយ៍ត្រី | ចេង លីហៀង | ៣២- អនុសេនីយ៍ត្រី | ទីវ បញ្ញា |
| ៣៣- ព្រឹន្ទបាលទោ | ស៊ន់ សិម៉ា | ៣៤- ព្រឹន្ទបាលទោ | រស់ សុវណ្ណរតនា |

ឈ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

| | | | |
|---|---|---|---|
| ១- លោក | អ៊ិន កុសល | ២- ឧត្តមសេនីយ៍ត្រី | វ័ត្ថ ចាន់ណា |
| ៣- វរសេនីយ៍ទោ | លឹម ទី | ៤- ព្រឹន្ទបាលឯក | ស៊ិន ធីនីសា |

៣-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១- លោក | ហេង កាលីម | ២- វរសេនីយ៍ទោ | ឡៅ មោសា |
| ៣- វរសេនីយ៍ទោ | ម៉ែក ចាន់វិសាល | ៤- វរសេនីយ៍ទោ | ហេង ណាត |
| ៥- អនុសេនីយ៍ឯក | ប្រាក់ ឥន្ទ | ៦- អនុសេនីយ៍ឯក | ប៉ិច ថន |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *០៥* ខែ *ឧសភា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

*ចារល. ២៦០៥. ៥៣៤*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន

- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ស្តីពីការដំឡើងថ្នាក់ស្មើ នាយកដ្ឋានដល់អង្គភាពថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១២៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការរៀបចំអង្គភាព សវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

## ជំពូកទី២

## មុខងារនិងរចនាសម្ព័ន្ធ

**មាត្រា២ .-**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបំពេញមុខងារដូចខាងក្រោម៖

១- ដឹកនាំនិងគ្រប់គ្រងវិស័យវប្បធម៌និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជារួមមាន៖

១.១- រៀបចំ តាមដាន អនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ។

១.២- ថែរក្សា ការពារ ជួសជុល ស្តារឡើងវិញ និងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ។

១.៣- លើកកម្ពស់ការផ្សព្វផ្សាយ ការប្រើប្រាស់សក្តានុពលវប្បធម៌ និងការអភិវឌ្ឍឧស្សាហកម្ម វប្បធម៌និងច្នៃប្រតិដ្ឋ ក្នុងការរួមចំណែកការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

១.៤- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យវប្បធម៌ ក្នុងកិច្ចការពារ ថែរក្សា និងលើកស្ទួយបេតិកភណ្ឌវប្បធម៌ជាតិ ព្រមទាំងការចាត់វិធានការ និងទប់ស្កាត់ ការបំផ្លិចបំផ្លាញ ការចរាចរសម្បត្តិវប្បធម៌ដោយខុសច្បាប់ និងរាល់សកម្មភាពដែលប៉ះពាល់ ដល់សិល្បៈវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីដ៏ថ្លៃថ្លារបស់ជាតិ។

១.៥- ប្រតិបត្តិនយោបាយការពារបេតិកភណ្ឌវប្បធម៌ជាតិ និងទាមទារយកមកវិញនូវសម្បត្តិវប្បធម៌ជាតិដែលត្រូវបានលួច និងកាន់កាប់ខុសច្បាប់ទាំងក្នុងនិងក្រៅប្រទេស។

១.៦- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យវប្បធម៌និងសិល្បៈ ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្តសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង និងលិខិតូបករណ៍អន្តរជាតិ។

២- គ្រប់គ្រង សហការ និងសម្របសម្រួលការអប់រំ ការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវវិស័យវប្បធម៌និងសិល្បៈរួមមាន៖

២.១- អប់រំ និងបណ្តុះបណ្តាលធនធានមនុស្សវិស័យវប្បធម៌និងសិល្បៈ កម្រិតបឋមនិងកម្រិតមធ្យមសិក្សាបច្ចេកទេស និងកម្រិតឧត្តមសិក្សា។

២.២- អភិវឌ្ឍកម្មវិធីសិក្សា និងពង្រឹងយន្តការផ្ទេរចំណេះដឹងវប្បធម៌ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតា។

២.៣- លើកកម្ពស់ការអប់រំ និងបញ្ជ្រាបការយល់ដឹងអំពីបេតិកភណ្ឌ និងសិល្បៈវប្បធម៌ជាតិដើម្បីចូលរួមបណ្តុះឧត្តមគតិវិជ្ជមាននិងមនសិការជាតិ។

២.៤- គ្រប់គ្រង និងសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិ ក្នុងការសិក្សា ស្រាវជ្រាវ ចងក្រងឯកសារជាលក្ខណៈវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

២.៥- ស្រាវជ្រាវ ចងក្រងឯកសារ និងចុះបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌ជាតិនិងសម្បត្តិវប្បធម៌ទូទៅបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ។

២.៦- ស្រាវជ្រាវ រៀបចំចងក្រងឯកសារស្នើសុំចុះបេតិកភណ្ឌវប្បធម៌ជាតិក្នុងបញ្ជីរបស់អង្គការយូណេស្កូនិងបញ្ជីថ្នាក់តំបន់របស់ស្ថាប័នអន្តរជាតិផ្សេងទៀត។

៣- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៣ .-**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានរចនាសម្ព័ន្ធដូចមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ដើម្បីអនុវត្តភារកិច្ចឆ្លើយតបនឹងមុខងារដែលជាសមត្ថកិច្ចរបស់ក្រសួង។

ការកំណត់ភារកិច្ចរបស់អង្គភាពក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ត្រូវអនុលោមតាមមាត្រា២នៃអនុក្រឹត្យនេះ។ អង្គភាពនីមួយៗ ត្រូវអនុវត្តភារកិច្ចដែលមានកំណត់រៀងៗខ្លួន។ ក្នុងករណីមានការត្រួតគ្នាក្នុងពេលអនុវត្ត រដ្ឋមន្ត្រីត្រូវពិនិត្យសម្រេចក្នុងការប្រគល់ភារកិច្ចឱ្យអង្គភាពតែមួយគត់របស់ខ្លួនដើម្បីអនុវត្ត។ ដោយឡែកក្នុងករណីមានការត្រួតគ្នាក្នុងពេលអនុវត្តរវាងក្រសួង ស្ថាប័ន នាយករដ្ឋមន្ត្រីពិនិត្យសម្រេច បន្ទាប់ពីទទួលបានយោបល់របស់ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៤ .-**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- អង្គភាពថ្នាក់ជាតិ

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានបេតិកភណ្ឌអរូបីនិងឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋ



ዓ

- អគ្គនាយកដ្ឋានបេតិកភណ្ឌ
- សាលាជាតិវិចិត្រសិល្បៈ
- អធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

២- អគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិយូណេស្កូកម្ពុជា

៣- គ្រឹះស្ថានសាធារណៈរដ្ឋបាល

- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- អាជ្ញាធរជាតិអប្សរា
- អាជ្ញាធរជាតិព្រះវិហារ
- អាជ្ញាធរជាតិសំបូរព្រៃគុក។

៤- អង្គភាពថ្នាក់ក្រោមជាតិ : មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

រូបសញ្ញានិងត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អគ្គលេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គនាយកដ្ឋានត្រូវដឹកនាំដោយអគ្គនាយក១(មួយ)រូប និងមានអគ្គនាយករងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អធិការដ្ឋានត្រូវដឹកនាំដោយអធិការ១(មួយ)រូប និងមានអធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយកដ្ឋានត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន១(មួយ)រូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សាលាជាតិវិចិត្រសិល្បៈត្រូវដឹកនាំដោយនាយកសាលា១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងមាននាយករងសាលាមួយចំនួនតាមការចាំបាច់ តែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននិងអង្គភាពនានា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៧ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈទទួលបន្ទុកបេសកកម្មទាំងឡាយដែលបានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន និងអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## អគ្គលេខាធិការដ្ឋាន

**មាត្រា៨ .-**

អគ្គលេខាធិការដ្ឋានមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តភារកិច្ចដូចមានកំណត់ក្នុងអនុក្រឹត្យលេខ១២៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការទទួលបន្ទុក។

**មាត្រា៩ .-**

អគ្គលេខាធិការដ្ឋានមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

១- នាយកដ្ឋានរដ្ឋបាល។

២- នាយកដ្ឋានធនធានមនុស្ស។

៣- នាយកដ្ឋានហិរញ្ញវត្ថុ។

៤- នាយកដ្ឋានផែនការនិងស្ថិតិ។

៥- នាយកដ្ឋាននីតិកម្ម។

៦- នាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ។

៧- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននិងបរិវត្តកម្មឌីជីថល។

**មាត្រា១០ .-**

នាយកដ្ឋានរដ្ឋបាលមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងផ្នែករដ្ឋបាលនិងសម្របសម្រួលស្ថានភាពរដ្ឋបាលគ្រប់ផ្នែករបស់ក្រសួង
- គ្រប់គ្រងនិងចរាចរឯកសារផ្សេងៗរបស់ក្រសួង ដែលនាយកដ្ឋានទទួលបន្ទុក
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- រៀបចំនិងគ្រប់គ្រង សន្តិសុខ សណ្ដាប់ធ្នាប់ បរិស្ថាន និងសោភណភាពក្រសួង
- ទទួលបន្ទុកសម្របសម្រួល ចាត់ចែងការងារពិធីការ រៀបចំកិច្ចប្រជុំ និងកម្មវិធីនានារបស់ក្រសួង
- សម្របសម្រួលរៀបចំ អភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធឌីជីថលសម្រាប់គាំទ្រនិងធានាដំណើរការប្រកបដោយប្រសិទ្ធភាពរបស់អង្គភាពក្រោមឱវាទក្រសួង
- គ្រប់គ្រង ជួសជុល និងថែរក្សាអគារ គ្រឿងសង្ហារិម សម្ភារៈការិយាល័យ គ្រឿងបរិក្ខារអគ្គិសនី អេឡិចត្រូនិកនិងព័ត៌មានវិទ្យា របស់អង្គភាពក្រោមឱវាទផ្ទាល់របស់ទីស្ដីការក្រសួង
- គ្រប់គ្រងយានដ្ឋាននិងយានយន្តរបស់រដ្ឋ ដែលប្រគល់ជូនក្រសួង
- ប្រមូលចងក្រង គ្រប់គ្រង និងរក្សាទុកឯកសារនិងទិន្នន័យទាំងឡាយរបស់ក្រសួង
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គលេខាធិការ ឬអគ្គលេខាធិការរងទទួលបន្ទុក។



៥

**មាត្រា១១ .-**

នាយកដ្ឋានធនធានមនុស្សមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងមន្ត្រីរាជការស៊ីវិល មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីផ្សេងទៀតរបស់ក្រសួង ជាអាទិ៍ ការជ្រើសរើស ការធ្វើកម្មសិក្សា ការប្រែប្រួលស្ថានភាពមន្ត្រី ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់ភារកិច្ច ការដាក់ទណ្ឌកម្ម ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការផ្តល់គ្រឿងឥស្សរិយយស
- រៀបចំរាល់លិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង
- រៀបចំផែនការក្របខ័ណ្ឌនិងធនធានមនុស្សរបស់ក្រសួង
- សិក្សា ស្រាវជ្រាវ រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សនិងស្ថាប័នរបស់ក្រសួង
- រៀបចំបៀវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភផ្សេងៗ
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ព្រមទាំងប្រព័ន្ធលើកទឹកចិត្តទាំងផ្នែកហិរញ្ញវត្ថុ មិនមែនហិរញ្ញវត្ថុ និងទណ្ឌកម្មខាងវិន័យ
- សហការរៀបចំការបណ្តុះបណ្តាល តាមដានអនុវត្តនិងវាយតម្លៃការបណ្តុះបណ្តាលមន្ត្រីរាជការរបស់ក្រសួង
- រៀបចំនិងរក្សាទុកឯកសារឯកត្តជនរបស់ថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការស៊ីវិល មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីផ្សេងទៀតរបស់ក្រសួង
- រៀបចំស្ថិតិលើការគ្រប់គ្រងមន្ត្រីនិងតារាងព័ត៌មានការងាររបស់មន្ត្រីក្នុងក្រសួង
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គលេខាធិការ ឬអគ្គលេខាធិការរងទទួលបន្ទុក។

**មាត្រា១២ .-**

នាយកដ្ឋានហិរញ្ញវត្ថុមានភារកិច្ចដូចខាងក្រោម៖

- រៀបចំ សម្របសម្រួល បូកសរុប និងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា
- ប្រមូលផ្តុំ សម្របសម្រួល បូកសរុប និងលើកគម្រោងថវិកាប្រចាំឆ្នាំ
- រៀបចំកម្មវិធីចំណូល ចំណាយសាច់ប្រាក់ប្រចាំត្រីមាស
- គាំទ្រនិងសម្របសម្រួលជាមួយអង្គភាពថវិកាក្នុងការគ្រប់គ្រងថវិកា
- ទទួលខុសត្រូវលើកិច្ចការប្រតិបត្តិការចំណូល ចំណាយប្រចាំឆ្នាំ និងកិច្ចបញ្ជិកាគណនេយ្យ
- រៀបចំ គ្រប់គ្រង និងអនុវត្តផែនការលទ្ធកម្ម
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិគ្រប់កម្រិត
- បែងចែកសម្ភារៈបរិក្ខារ និងប្រេងឥន្ធនៈ ជូនបណ្តាអង្គភាពនានាក្រោមឱវាទក្រសួង
- រៀបចំនិងបើកប្រាក់បៀវត្ស និងប្រាក់សង្គមកិច្ច ជូនមន្ត្រីរាជការក្រោមឱវាទក្រសួង



៤

- រៀបចំគម្រោងនិងកម្មវិធីសាងសង់ ជួសជុល ថែទាំសំណង់ អគារ និងសម្ភារៈបរិក្ខារគ្រប់ប្រភេទ
- រៀបចំចុះកិច្ចបញ្ជិកាជាប្រចាំឆ្នាំ
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គលេខាធិការ ឬអគ្គលេខាធិការរងទទួលបន្ទុក។

**មាត្រា១៣ .-**

នាយកដ្ឋានផែនការនិងស្ថិតិមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងសម្របសម្រួលគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍស្ថាប័ន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង
- រៀបចំសូចនាករនិងកិច្ចព្រមព្រៀងសមិទ្ធកម្មរបស់ក្រសួង
- សិក្សា ស្រាវជ្រាវ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តផែនការរបស់ក្រសួង
- ចងក្រងនិងវិភាគទិន្នន័យ ស្ថិតិ ដើម្បីកំណត់កម្មវិធីសកម្មភាពនិងការធ្វើទំនើបកម្មផែនការ
- រៀបចំឯកសារទស្សនាទាន យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌក្រសួង
- គ្រប់គ្រងនិងចងក្រងឯកសារស្តីពីគម្រោងជំនួយ គម្រោងសហការ និងស្ថានភាពនៃការអនុវត្តគម្រោង
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការកម្មវិធីវិនិយោគសាធារណៈ
- ប្រមូលផ្តុំ ចងក្រង និងសរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- សហការផ្តល់ព័ត៌មានស្ថិតិជូនក្រសួងផែនការតាមការកំណត់
- រៀបចំរបាយការណ៍និងឯកសារពាក់ព័ន្ធសម្រាប់ការរៀបចំសន្និបាតរបស់ក្រសួង
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គលេខាធិការ ឬអគ្គលេខាធិការរងទទួលបន្ទុក។

**មាត្រា១៤ .-**

នាយកដ្ឋាននីតិកម្មមានភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យវប្បធម៌និងវិចិត្រសិល្បៈ
- រៀបចំផែនការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តវិស័យវប្បធម៌និងវិចិត្រសិល្បៈ
- ជំរុញនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តវិស័យវប្បធម៌និងវិចិត្រសិល្បៈ



90

- ពិនិត្យ ផ្តល់យោបល់ កែសម្រួលលើទម្រង់និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិស័យវប្បធម៌និងវិចិត្រសិល្បៈ ដែលរៀបចំឡើងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ពិនិត្យតាមដាននិងវាយតម្លៃផលប៉ះពាល់នៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តវិស័យវប្បធម៌ និងវិចិត្រសិល្បៈ
- សិក្សា ពិនិត្យលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យវប្បធម៌និងវិចិត្រសិល្បៈ ដែល មិនសមស្របនឹងវឌ្ឍនភាពសង្គម ដើម្បីលើកយោបល់ជូនរដ្ឋមន្ត្រី គោរពជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យនិងសម្រេចលើការធ្វើវិសោធនកម្មឬកែសម្រួល
- ប្រមូលផ្តុំ ចងក្រង បោះពុម្ព និងតម្កល់ទុករាល់ឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យវប្បធម៌និងវិចិត្រសិល្បៈនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការក្នុងការសិក្សាជាមួយអង្គភាពចំណុះរបស់ក្រសួងដែលមានតម្រូវការច្បាប់ឬលិខិតបទដ្ឋាន គតិយុត្ត ព្រមទាំងចូលរួមតាក់តែងសេចក្តីព្រាង និងរៀបចំកិច្ចប្រជុំឬសិក្ខាសាលា ដើម្បីប្រមូលធាតុចូល ឱ្យបានគ្រប់ជ្រុងជ្រោយ
- សហការនិងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំទម្រង់បែបបទនិងនីតិវិធីនៃ ការផ្តល់សេវាសាធារណៈនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- សហការនិងសម្របសម្រួលការងារកែទម្រង់ច្បាប់ ការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់ផ្សេងៗរបស់ក្រសួង
- ចូលរួមពិនិត្យនិងផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងវិស័យវប្បធម៌និងវិចិត្រសិល្បៈ ដែលផ្តួចផ្តើមដោយក្រសួង ស្ថាប័នផ្សេងទៀត
- សហការជាមួយអង្គភាពចំណុះក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការ រៀបចំប្រតិទិននៃការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យវប្បធម៌និង វិចិត្រសិល្បៈ
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្ត ភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និង ប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គលេខាធិការ ឬអគ្គលេខាធិការរងទទួលបន្ទុក។

**មាត្រា១៥ .-**

នាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិមានភារកិច្ចដូចខាងក្រោម៖

- ធ្វើទំនាក់ទំនងនិងបង្កើតកិច្ចសហប្រតិបត្តិការវប្បធម៌ជាមួយស្ថាប័នជាតិ ជាមួយអង្គការមិនមែន រដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិ និងជាមួយបណ្តាប្រទេសសមាជិកអាស៊ាន ក្នុងតំបន់និង លើសាកលលោក

- រៀបចំនិងគ្រប់គ្រងរាល់ឯកសារនៃកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា ជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិ និងជាមួយបណ្ដាប្រទេសក្នុងតំបន់ និងលើសាកលលោក លើវិស័យវប្បធម៌និងវិចិត្រសិល្បៈ
- សម្របសម្រួលនិងរៀបចំការចុះកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា ពិធីសារអន្តរជាតិ ជាមួយនឹងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិនានា
- ពិនិត្យតាមដាន និងផ្សព្វផ្សាយការអនុវត្តកិច្ចព្រមព្រៀង និងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ជាមួយនឹងដៃគូជាតិនិងអន្តរជាតិ ព្រមទាំងជំរុញការអនុវត្តឱ្យទទួលបានជោគជ័យ
- សម្របសម្រួលការងារកិច្ចសហប្រតិបត្តិការអន្តរជាតិនិងកិច្ចការអាស៊ាន
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ បណ្ដាអង្គទូតនានា ដើម្បីស្វែងរកជំនួយជាថវិកា សម្ភារៈ ឬបច្ចេកទេស ដែលធានាដល់ការការពារ អភិរក្ស និងលើកកម្ពស់វប្បធម៌ជាតិទាំងរូបីនិងអរូបី
- សម្របសម្រួលជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ សាស្ត្រាចារ្យ និស្សិត សិស្ស ក្នុងការទៅបំពេញទស្សនកិច្ច ចូលរួមកិច្ចប្រជុំ និងកម្មវិធីនានានៅក្រៅប្រទេសក្នុងសកម្មភាពវប្បធម៌ ឬទៅធ្វើកម្មសិក្សាផ្សេងៗ
- រៀបចំនិងសម្របសម្រួលបែបបទជូនគណៈប្រតិភូអន្តរជាតិចូលរួមក្នុងសន្និសីទ កិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ច ឬក្នុងព្រឹត្តិការណ៍វប្បធម៌ផ្សេងៗ
- រៀបចំបែបបទពិធីការ ឯកសារធ្វើដំណើរ និងទម្រង់បែបបទនានាសម្រាប់គណៈប្រតិភូរបស់ក្រសួង ដែលចេញទៅបំពេញទស្សនៈកិច្ចឬចូលរួមក្នុងព្រឹត្តិការណ៍វប្បធម៌ផ្សេងៗក្រៅប្រទេស និងចងក្រងឯកសាររបាយការណ៍សម្រាប់ការងារបន្ត
- រៀបចំឯកសារនិងជំនួយស្មារតី សម្រាប់កិច្ចប្រជុំសំខាន់ៗរបស់ថ្នាក់ដឹកនាំជាមួយភាគីពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំសហប្រតិបត្តិការផ្នែកវប្បធម៌របស់អាស៊ាន និងកិច្ចប្រជុំអន្តរជាតិដទៃផ្សេងទៀត
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គលេខាធិការ ឬអគ្គលេខាធិការរងទទួលបន្ទុក។

**មាត្រា១៦ .-**

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននិងបរិវត្តកម្មឌីជីថលមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងបរិវត្តកម្មឌីជីថលរបស់ក្រសួង
- គ្រប់គ្រង និងធ្វើប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងផ្ដល់សេវាឌីជីថលដែលគាំទ្រដល់និរន្តរភាពការងារជាប្រចាំរបស់អង្គភាពក្រោមឱវាទរបស់ក្រសួង
- គ្រប់គ្រងសេវា បណ្ដាញតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត បញ្ជូន និងរក្សាទុកទិន្នន័យវប្បធម៌និងសិល្បៈជាតិ ដើម្បីធានាសន្តិសុខនិងសណ្ដាប់ធ្នាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន



៩

- រៀបចំ អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសម្របសម្រួលការងារបរិវត្តកម្មឌីជីថល ដើម្បីធានា និងគាំទ្រកិច្ចដំណើរការប្រកបដោយប្រសិទ្ធភាព
- កសាងកម្មវិធីផ្នែកទន់ គាំទ្រការធ្វើឌីជីតូបនីយកម្ម និងឌីជីថលូបនីយកម្មលើប្រព័ន្ធបច្ចេកវិទ្យា
- សម្របសម្រួលរៀបចំនិងគ្រប់គ្រងបណ្ដាញប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យារបស់អង្គភាពពាក់ព័ន្ធ
- សម្របសម្រួលក្នុងការធ្វើការត្រួតពិនិត្យលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានាថាស្តង់ដារនិង គោលការណ៍សន្តិសុខសាយប័រដោធរមានត្រូវបានអនុវត្ត
- សម្របសម្រួល គ្រប់គ្រង និងថែទាំសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថលផ្ទៃក្នុងក្រសួង ព្រមទាំងរបស់អង្គភាពក្រោមឱវាទរបស់ក្រសួង
- សហការ និងសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនិងជំនាញឌីជីថលសំខាន់ៗ ជូនមន្ត្រីរាជការក្រោមឱវាទរបស់ក្រសួង
- តាមដាននិងវាយតម្លៃអំពីវឌ្ឍនភាពការងារបរិវត្តកម្មឌីជីថលតាមអង្គភាពក្រោមឱវាទក្រសួង
- សហការជាមួយអន្តរក្រសួងនិងស្ថាប័នពាក់ព័ន្ធនានា លើការងារធ្វើបរិវត្តកម្មឌីជីថល
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្ត ភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និង ប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គលេខាធិការ ឬអគ្គលេខាធិការរងទទួលបន្ទុក។

## ជំពូកទី៥
## អគ្គនាយកដ្ឋានបេតិកភណ្ឌអរូបីនិងឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋ

**មាត្រា១៧ .-**

អគ្គនាយកដ្ឋានបេតិកភណ្ឌអរូបីនិងឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋមានភារកិច្ចដូចខាងក្រោម៖
- ថែរក្សា ការពារ ស្តារឡើងវិញ និងលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបីជាតិ
- សម្របសម្រួល និងសហការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា គោលនយោបាយ និងផែនការ យុទ្ធសាស្ត្រ ក្នុងការគ្រប់គ្រង ថែរក្សាការពារ លើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី និងអភិវឌ្ឍ ឧស្សាហកម្មវប្បធម៌
- ជំរុញកិច្ចការពារសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ដើម្បីលើកកម្ពស់ការបង្កើតស្នាដៃថ្មី និង ផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់សិទ្ធិអ្នកនិពន្ធនិងម្ចាស់សិទ្ធិប្រហាក់ប្រហែល
- សិក្សា ស្រាវជ្រាវ ចងក្រង ចុះបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបីនិងទិន្នន័យឧស្សាហកម្មវប្បធម៌ ច្នៃប្រតិដ្ឋ
- ស្រាវជ្រាវ រៀបចំឯកសារស្នើសុំចុះបេតិកភណ្ឌវប្បធម៌អរូបីជាតិទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី នៃមនុស្សជាតិរបស់អង្គការយូណេស្កូឬស្ថាប័នអន្តរជាតិផ្សេងទៀត
- លើកកម្ពស់ការផ្សព្វផ្សាយសិល្បៈវប្បធម៌ និងអភិវឌ្ឍឧស្សាហកម្មវប្បធម៌ និងច្នៃប្រតិដ្ឋ
- សិក្សា ស្រាវជ្រាវ ចងក្រងឯកសារ ដំឡើងស្នាដៃថ្មី និងផ្សព្វផ្សាយសិល្បៈវប្បធម៌តាមគ្រប់មធ្យោបាយ

- សម្របសម្រួល សហការ រៀបចំការផ្ទេរចំណេះដឹង និងការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យសិល្បៈវប្បធម៌ទាំងក្នុងនិងក្រៅប្រព័ន្ធ
- ទប់ស្កាត់ និងចាត់វិធានការចំពោះសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈវប្បធម៌ជាតិ
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ ទំនាក់ទំនងភាពជាដៃគូ និងអនុវត្តសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិនានាទាក់ទងនឹងបេតិកភណ្ឌវប្បធម៌អរូបី និងឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋ
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់អគ្គនាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការទទួលបន្ទុក។

**មាត្រា១៨ .-**

អគ្គនាយកដ្ឋានបេតិកភណ្ឌអរូបីនិងឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋមាននាយកដ្ឋានចំណុះដូចខាងក្រោមៈ

១- នាយកដ្ឋានអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី។
២- នាយកដ្ឋានជំរុញផលិតផលវប្បធម៌ច្នៃប្រតិដ្ឋ។
៣- នាយកដ្ឋានសិល្បៈទស្សនីយភាព។
៤- នាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌។
៥- នាយកដ្ឋានសៀវភៅនិងការអាន។
៦- នាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល។

**មាត្រា១៩ .-**

នាយកដ្ឋានអភិរក្សបេតិកភណ្ឌវប្បធម៌អរូបីមានភារកិច្ចដូចខាងក្រោមៈ

- ការពារ អភិរក្ស និងផ្សព្វផ្សាយតម្លៃបេតិកភណ្ឌវប្បធម៌អរូបី
- រៀបចំនិងសម្របសម្រួលធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបី
- ការពារនិងលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបីរបស់សហគមន៍ និងបុគ្គលដែលពាក់ព័ន្ធ
- សិក្សា ស្រាវជ្រាវ ចងក្រងឯកសារបេតិកភណ្ឌវប្បធម៌អរូបីជាតិ និងស្នើចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ
- ជំរុញការអនុវត្តនិងធ្វើរបាយការណ៍វឌ្ឍនភាពជាកាតព្វកិច្ចនូវរាល់បេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិដែលបានចុះក្នុងបញ្ជីរបស់អង្គការយូណេស្កូ
- រៀបចំនិងសម្របសម្រួលការអនុវត្តអំពីប្រព័ន្ធមរតកមនុស្សរស់ក្នុងការចងក្រងឯកសារ ការបណ្តុះបណ្តាល ការបង្កើតស្នាដៃ ការផ្សព្វផ្សាយ និងការផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេស
- សិក្សាស្រាវជ្រាវ និងចងក្រងបេតិកភណ្ឌវប្បធម៌អរូបី និងការប្រឈមនឹងបាត់បង់ និងដែលបាត់បង់
- ចងក្រងឯកសារសិល្បៈទស្សនីយភាព សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ដើម្បីទុកជាក្បួនខ្នាតសម្រាប់កំណត់បទដ្ឋានបច្ចេកទេស
- សហការប្រតិបត្តិការភាពជាដៃគូជាមួយវិស័យឯកជន សមាគមន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិ ដើម្បីការអភិរក្សនិងលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី

- សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធក្នុងការថែរក្សា ការពារ និងលើកតម្លៃវប្បធម៌ សិល្បៈ ប្រពៃណីរបស់ជនជាតិដើមភាគតិច
- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួងដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

**មាត្រា២០ .-**

នាយកដ្ឋានជំរុញផលិតផលវប្បធម៌ច្នៃប្រតិដ្ឋមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងរៀបចំយន្តការលើកកម្ពស់សិល្បៈសិប្បកម្ម និងផលិតផលវប្បធម៌ច្នៃប្រតិដ្ឋ
- ណែនាំ តម្រង់ទិស និងគ្រប់គ្រងលើគោលការណ៍ជំនាញ ដើម្បីពង្រឹងនិងលើកកម្ពស់គុណភាពក្នុងការបង្កើតស្នាដៃថ្មីៗនៃផលិតផលនិងសេវាកម្មវប្បធម៌
- ត្រួតពិនិត្យនិងណែនាំការសម្តែង ការបង្ហាញម៉ូតសម្លៀកបំពាក់ ម៉ូតសក់ និងគ្រឿងអលង្ការ ដែលមានលក្ខណៈច្នៃប្រតិដ្ឋផ្អែកលើមូលដ្ឋានប្រពៃណី សិល្បៈ និងវប្បធម៌
- ជំរឿន និងធ្វើបច្ចុប្បន្នភាពសិល្បៈសិប្បកម្ម និងសាជីវកម្មផលិតផលសិល្បៈវប្បធម៌
- ជំរុញការប្រើប្រាស់ផលិតផលវប្បធម៌ និងច្នៃប្រតិដ្ឋ និងសិក្សាទីផ្សារ
- ពង្រឹងនិងពង្រីកការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង បទពិសោធ បច្ចេកទេស និងការវិនិយោគលើវិស័យវប្បធម៌
- រៀបចំនិងជំរុញការចូលរួមក្នុងព្រឹត្តិការណ៍នានា ដើម្បីផ្សព្វផ្សាយផលិតផលវប្បធម៌ និងច្នៃប្រតិដ្ឋរបស់កម្ពុជាទាំងក្នុងនិងក្រៅប្រទេស
- ពង្រឹងកិច្ចសហការ និងសម្របសម្រួលបណ្តាញប្រតិបត្តិករនិងធុរជន ដើម្បីលើកកម្ពស់ផលិតផលវប្បធម៌ និងសិល្បៈសិប្បកម្ម
- រៀបចំនិងជំរុញយន្តការបណ្តុះបណ្តាលចំណេះវិជ្ជាជីវៈជំនាញដូនតា
- សហការ និងសម្របសម្រួលជំរុញឱ្យមានមណ្ឌលអភិវឌ្ឍន៍វប្បធម៌ និងសិល្បៈសិប្បកម្មនៅតាមសហគមន៍
- សម្របសម្រួលនិងតាមដានការអនុវត្តកាតព្វកិច្ចនៃកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារពាក់ព័ន្ធនឹងការអភិវឌ្ឍវប្បធម៌ និងច្នៃប្រតិដ្ឋ
- លើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ និងជំរុញការច្នៃប្រតិដ្ឋបង្កើតថ្មីផ្អែកវប្បធម៌និងសិល្បៈ
- ជំរុញការអនុវត្តសេដ្ឋកិច្ចច្នៃប្រតិដ្ឋនៅក្នុងវិស័យសិល្បៈវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ
- សហការរៀបចំលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំ ក្នុងការអភិវឌ្ឍន៍ផលិតផលវប្បធម៌ច្នៃប្រតិដ្ឋ និងសិល្បៈសិប្បកម្ម

- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

**មាត្រា២១ .-**

នាយកដ្ឋានសិល្បៈទស្សនីយភាពមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង ថែរក្សា ការពារ លើកស្ទួយ និងអភិវឌ្ឍសិល្បៈទស្សនីយភាព
- សហការក្នុងការសិក្សា ស្រាវជ្រាវ ចងក្រងឯកសារ ក្បួនខ្នាត ដំឡើងស្នាដៃសិល្បៈទស្សនីយភាពគ្រប់ទម្រង់ និងស្តារឡើងវិញនូវសិល្បៈទស្សនីយភាពដែលកំពុងប្រឈមនឹងការបាត់បង់
- រៀបចំយន្តការផ្សព្វផ្សាយសិល្បៈទស្សនីយភាពគ្រប់ទម្រង់ឱ្យបានទូលំទូលាយទាំងនៅក្នុង និងក្រៅប្រទេស តាមរយៈការសម្តែងផ្ទាល់ និងការផ្សព្វផ្សាយនៅលើគ្រប់មធ្យោបាយ
- សហការរៀបចំចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិសិល្បៈទស្សនីយភាពទូទាំងប្រទេសសម្រាប់តម្កល់ទុកជាឯកសារ
- ជំរុញនិងលើកទឹកចិត្តការបង្កើតស្នាដៃថ្មីៗ ធ្វើឱ្យមានភាពសម្បូរបែបនៃទម្រង់សិល្បៈទស្សនីយភាព
- សហការ និងចូលរួមរៀបចំព្រឹត្តិការណ៍វប្បធម៌ជាតិនិងអន្តរជាតិនានា ដូចជាការសម្តែងសិល្បៈរបាំ ល្ខោន ប្រគំតន្ត្រីបុរាណនិងសម័យ និងមហោស្រពសិល្បៈទស្សនីយភាព
- សហការរៀបចំការបណ្តុះបណ្តាលវគ្គខ្លីៗជំនាញសិល្បៈទស្សនីយភាព ដើម្បីពង្រឹងសមត្ថភាពសិល្បករ សិល្បការិនីទាំងក្នុងនិងក្រៅប្រព័ន្ធ
- សហការ និងចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំ ក្នុងការគ្រប់គ្រងវិស័យសិល្បៈទស្សនីយភាព
- ពិនិត្យ និងផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត ការផ្អាកជាបណ្តោះអាសន្ន បញ្ឈប់ ការធ្វើអាជីវកម្ម និងសេវាកម្មទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យសិល្បៈទស្សនីយភាព
- ទំនាក់ទំនងនិងសហការជាមួយដៃគូជាតិ អន្តរជាតិ វិស័យឯកជន អង្គការ សមាគមនានា ដើម្បីលើកស្ទួយនិងអភិវឌ្ឍសិល្បៈទស្សនីយភាព
- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុ របស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

**មាត្រា២២ .-**

នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌មានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យភាពយន្ត ដែលជាសិល្បៈទី៧ ក្នុងព្រះរាជាណាចក្រកម្ពុជា
- ផលិត ផ្សព្វផ្សាយ គ្រប់គ្រង និងត្រួតពិនិត្យវិស័យវប្បធម៌តាមរូបភាព ភាពយន្ត វីដេអូ និងពហុមេឌីយ៉ា ដោយសហការជាមួយក្រសួងពាក់ព័ន្ធ
- គាំទ្រនិងលើកទឹកចិត្តដល់សកម្មភាពផលិត ការធ្វើអាជីវកម្ម ការធ្វើសេវាកម្ម ការផ្សព្វផ្សាយស្នាដៃភាពយន្ត វីដេអូ
- ពិនិត្យនិងផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត ទិដ្ឋាការផ្សព្វផ្សាយ ការផ្អាកជាបណ្តោះអាសន្ន បញ្ឈប់ការធ្វើអាជីវកម្ម និងសេវាកម្មទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យភាពយន្ត
- ស្រាវជ្រាវ ប្រមូលចងក្រងឯកសារបេតិកភណ្ឌភាពយន្តជាតិ និងចុះបញ្ជីទិន្នន័យឧស្សាហកម្មភាពយន្ត
- ទប់ស្កាត់និងចាត់វិធានការនានាចំពោះការផ្សព្វផ្សាយស្នាដៃភាពយន្ត វីដេអូដែលនាំឱ្យប៉ះពាល់ដល់ប្រពៃណី ទំនៀមទម្លាប់ សេចក្តីថ្លៃថ្នូរ និងសន្តិសុខជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ទំនាក់ទំនង សហការ និងសម្របសម្រួលជំរុញផលិតផលភាពយន្តកម្ពុជា នៅទីផ្សារក្នុងស្រុក និងទៅកាន់ទីផ្សារអន្តរជាតិ ព្រមទាំងទាក់ទាញផលិតករភាពយន្តបរទេសឱ្យមកថតភាពយន្តនៅកម្ពុជា
- សហការ និងចូលរួមរៀបចំយន្តការនិងលិខិតបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រង និងលើកកម្ពស់ដល់ការអភិវឌ្ឍឧស្សាហកម្មភាពយន្តជាតិ
- សហការ សម្របសម្រួល និងគាំទ្រដល់គ្រប់សកម្មភាពបណ្តុះបណ្តាលជំនាញពាក់ព័ន្ធឧស្សាហកម្មភាពយន្ត
- ជំរុញលើកទឹកចិត្ត និងតម្រង់ទិសដល់ការផលិត និងការផ្សព្វផ្សាយសិល្បៈវប្បធម៌កម្ពុជាតាមរយៈភាពយន្តទាំងក្នុងនិងក្រៅប្រទេស
- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

**មាត្រា២៣ .-**

នាយកដ្ឋានសៀវភៅ និងការអានមានភារកិច្ចដូចខាងក្រោម៖

- ថែរក្សា ការពារ និងលើកតម្កើងស្នាដៃសរសេរ បេតិកភណ្ឌឯកសារ និងសាស្ត្រាស្លឹករឹត
- គ្រប់គ្រងនិងចុះបញ្ជីការបោះពុម្ពផ្សាយសៀវភៅនៅកម្ពុជា តាមរយៈស្តង់ដារលេខសៀវភៅខ្នាតអន្តរជាតិ
- គ្រប់គ្រងនិងសហការការបោះពុម្ពផ្សព្វផ្សាយសៀវភៅ ការជំរុញលើកកម្ពស់ការអាន ការនិពន្ធ
- គ្រប់គ្រងបណ្ណាល័យនៅតាមរាជធានី ខេត្ត

- គ្រប់គ្រង ត្រួតពិនិត្យ និងអនុញ្ញាតបើកបណ្ណាគារគ្រប់ប្រភេទ
- រៀបចំព្រឹត្តិការណ៍នានាដើម្បីជំរុញសាធារណជនចូលរួមលើកកម្ពស់ឧស្សាហកម្មសៀវភៅ
- គាំទ្រនិងលើកទឹកចិត្តដល់អ្នកនិពន្ធ អ្នកបោះពុម្ពផ្សាយសៀវភៅដែលបម្រើផលប្រយោជន៍សង្គម
- សិក្សាស្រាវជ្រាវ ធ្វើបញ្ជីសារពើភណ្ឌបេតិកភណ្ឌឯកសារ និងសាស្ត្រាស្លឹករឹត
- សហការចងក្រងបញ្ជីគន្ថនិទ្ទេសជាតិរាល់ការបោះពុម្ពផ្សាយដែលទាក់ទងនឹងកម្ពុជា
- ពង្រីកសេវាកម្ម និងជួយគាំទ្រដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងសាធារណជន
- សហការ និងចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំ ក្នុងការត្រួតពិនិត្យ និងអនុញ្ញាតបើកបណ្ណាល័យនិងបណ្ណាគារគ្រប់ប្រភេទ
- សហការរៀបចំយន្តការតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងគោលការណ៍ ណែនាំ ដើម្បីអភិរក្សបេតិកភណ្ឌឯកសារនិងអភិវឌ្ឍការអាន ព្រមទាំងឧស្សាហកម្មសៀវភៅនៅកម្ពុជា
- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

**មាត្រា២៤ .-**

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងកម្មវិធីនយោបាយស្តីពីវិស័យសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលស្របតាមការវិវឌ្ឍនៃសង្គម សេដ្ឋកិច្ច បច្ចេកវិទ្យា និងក្របខ័ណ្ឌបទប្បញ្ញត្តិជាតិនិងអន្តរជាតិ
- ពង្រឹងយន្តការការគ្រប់គ្រងនិងការអនុវត្តច្បាប់ គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ព្រមទាំងបទប្បញ្ញត្តិអនឡាញពាក់ព័ន្ធនឹងវិធានការកិច្ចការពារបច្ចេកវិទ្យា និងព័ត៌មានស្តីពីរបបសិទ្ធិ ដើម្បីអភិវឌ្ឍវិស័យសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅកម្ពុជា
- អនុវត្តឱ្យបានទូលំទូលាយនូវនយោបាយសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ដើម្បីធានាការពារនូវផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និងលើកទឹកចិត្តដល់អ្នកនិពន្ធឬអ្នកបង្កើតស្នាដៃឱ្យបង្កើនការផលិតនូវផលិតផលខាងវិស័យវប្បធម៌
- សហការចូលរួមរៀបចំនយោបាយសុខដុមនីយកម្មប្រព័ន្ធសិទ្ធិអ្នកនិពន្ធកម្ពុជា ដើម្បីធានានូវការប្រើប្រាស់ប្រកបដោយសមធម៌ ក្នុងទិសដៅលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន ការអប់រំប្រកបដោយប្រសិទ្ធភាព និងគុណភាព ជាពិសេសក្នុងបរិស្ថានឌីជីថល
- ចូលរួមសម្របសម្រួល សិក្សាស្រាវជ្រាវ និងការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាជាភាគីនៃសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយបទប្បញ្ញត្តិនានា ព្រមទាំងចំណេះដឹងសិទ្ធិអ្នកនិពន្ធ ដល់សាធារណជន អ្នកនិពន្ធ សិល្បករ មន្ត្រីអនុវត្តច្បាប់ និងអ្នកពាក់ព័ន្ធដទៃទៀត
- ធ្វើបរិវត្តកម្មបច្ចេកវិទ្យាឌីជីថលសម្រាប់ការផ្តល់ព័ត៌មាន និងសេវាជាសាធារណៈ ដើម្បីពង្រឹងគុណភាពសេវា និងអភិវឌ្ឍចំណេះដឹងសិទ្ធិអ្នកនិពន្ធនៅកម្ពុជា
- រៀបចំព្រឹត្តិការណ៍ទាក់ទងសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងទិវាកម្មសិទ្ធិបញ្ញាសម្រាប់ផ្លាស់ប្តូរបទពិសោធ ដើម្បីលើកស្ទួយ និងអភិវឌ្ឍន៍ស្នាដៃ និងបច្ចេកវិទ្យា
- សហការសម្របសម្រួលជាមួយដៃគូឯកជន អាជ្ញាធរមានសមត្ថកិច្ច តុលាការ អង្គការជាតិ អង្គការអន្តរជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀត
- សម្រុះសម្រួលវិវាទសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលក្រៅប្រព័ន្ធតុលាការ
- គ្រប់គ្រងនិងសម្របសម្រួលការងារលើកិច្ចការធុរកិច្ច អាជ្ញាបណ្ណអាជីវកម្ម ភ្នាក់ងារសិទ្ធិអ្នកនិពន្ធ និងកិច្ចការអង្គភាពគ្រប់គ្រងសិទ្ធិរួម
- ផ្តល់ការប្រឹក្សាយោបល់ផ្នែកសិទ្ធិអ្នកនិពន្ធជូនសាធារណជន មេធាវី មន្ត្រីអនុវត្តច្បាប់ វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត
- ចុះបញ្ជីស្នាដៃ និងផ្តល់អាជ្ញាបណ្ណសេវាសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

## ជំពូកទី៦

## អគ្គនាយកដ្ឋានបេតិកភណ្ឌ

**មាត្រា២៥ ._**

អគ្គនាយកដ្ឋានបេតិកភណ្ឌមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តរាល់បេសកកម្មរបស់ក្រសួងក្នុងកិច្ចអភិរក្ស ថែរក្សាការពារ និងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ រមណីយដ្ឋានបេតិកភណ្ឌ និងសម្បត្តិវប្បធម៌ទូទៅ
- ពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់
- ស្រាវជ្រាវ ធ្វើកំណាយបុរាណវិទ្យា ធ្វើផែនទី និងសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងការកំណត់តំបន់ បោះបង្គោលព្រំ



៤

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើប្លង់កម្មសិទ្ធិ និង/ឬប្លង់សម្គាល់ទីតាំងបេតិកភណ្ឌវប្បធម៌លើដី ក្រោមដី និងក្រោមទឹក ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ស្រាវជ្រាវ ចងក្រង និងបោះពុម្ពសលាកបត្រព័ត៌មានបេតិកភណ្ឌវប្បធម៌ជាតិនិងសម្បត្តិវប្បធម៌ទូទៅ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការចុះបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌និងធ្វើចំណាត់ថ្នាក់ជាបេតិកភណ្ឌជាតិ
- រៀបចំការបញ្ចូលសារពើភណ្ឌសម្បត្តិវប្បធម៌និងបេតិកភណ្ឌជាតិ ក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យ
- រៀបចំចងក្រងឯកសារស្នើសុំចុះបេតិកភណ្ឌវប្បធម៌ជាតិ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ និងបញ្ជីថ្នាក់តំបន់របស់ស្ថាប័នអន្តរជាតិផ្សេងទៀត
- ស្រាវជ្រាវ ផ្សព្វផ្សាយនិងសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ក្នុងការទាមទារយកមកវិញនូវវត្ថុបុរាណខ្មែរដែលត្រូវបានលួច និងកាន់កាប់ខុសច្បាប់នៅក្នុងនិងក្រៅប្រទេស
- លើកកម្ពស់ការអប់រំ ផ្សព្វផ្សាយបេតិកភណ្ឌវប្បធម៌ជាតិ និងជំរុញការអភិវឌ្ឍន៍សារមន្ទីរ ការគ្រប់គ្រងសមុច្ច័យ និងការតាំងពិព័រណ៍
- សហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិនិងអន្តរជាតិ ក្នុងកិច្ចគាំពារ ថែរក្សាការពារ ផ្សព្វផ្សាយ និងលើកតម្លៃបេតិកភណ្ឌវប្បធម៌
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំតំបន់ទីក្រុងបេតិកភណ្ឌ និងរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌
- សហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងការគ្រប់គ្រងទឹក ព្រៃឈើ បរិស្ថាន ក្នុងរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌ត្រូវការពារ ដើម្បីធានាសុវត្ថិភាពនិងនិរន្តរភាពនៃសំណង់បេតិកភណ្ឌវប្បធម៌
- សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការទប់ស្កាត់ការបំផ្លិចបំផ្លាញប្រាសាទបុរាណ រមណីយដ្ឋានបេតិកភណ្ឌវប្បធម៌ សំណង់បេតិកភណ្ឌ សំណង់ប្រវត្តិសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធបុរាណ បុរាណស្ថាន និងបុរាណវត្ថុ
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់អគ្គនាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការទទួលបន្ទុក។

**មាត្រា២៦ .-**

អគ្គនាយកដ្ឋានបេតិកភណ្ឌមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

១- នាយកដ្ឋានបុរាណវត្ថុនិងបញ្ជីសារពើភណ្ឌ។

២- នាយកដ្ឋានសារមន្ទីរ។

៣- នាយកដ្ឋានអភិរក្សសំណង់បេតិកភណ្ឌ។

៤- នាយកដ្ឋានបុរាណវិទ្យា។

**មាត្រា២៧.-**

នាយកដ្ឋានបុរាណវត្ថុនិងបញ្ជីសារពើភណ្ឌមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងមូលដ្ឋានប្រព័ន្ធទិន្នន័យ និងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ដោយធ្វើចំណាត់ថ្នាក់ទៅជាបេតិកភណ្ឌវប្បធម៌ជាតិ
- សហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំក្នុងការគ្រប់គ្រងការនាំចេញ នាំចូលវត្ថុសិល្បៈ
- សហការ និងចូលរួមត្រួតពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសម្រាប់ការនាំចេញ នាំចូលវត្ថុសិល្បៈ
- សិក្សាស្រាវជ្រាវ ចងក្រងឯកសារ ថែរក្សា និងអភិរក្សវត្ថុបុរាណ
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធក្នុងការអប់រំ ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណងពង្រឹងការថែរក្សា ការពារបេតិកភណ្ឌ និងលើកតម្លៃសម្បត្តិវប្បធម៌ជាតិ
- សហការជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការទប់ស្កាត់ និងចាត់វិធានការលើបទល្មើសបំផ្លិចបំផ្លាញ ចរាចរ និងជួញដូរវត្ថុបុរាណដោយខុសច្បាប់
- សហការសម្របសម្រួលក្នុងការទាមទារបញ្ជូនត្រឡប់មកវិញនូវវត្ថុបុរាណខ្មែរដែលត្រូវបានលួច និងកាន់កាប់ខុសច្បាប់ទាំងក្នុង និងក្រៅប្រទេស
- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

**មាត្រា២៨.-**

នាយកដ្ឋានសារមន្ទីរមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងសហការជាមួយបណ្តាសារមន្ទីររដ្ឋ និងសារមន្ទីរឯកជនគ្រប់ប្រភេទនៅទូទាំងប្រទេស
- គ្រប់គ្រង អភិរក្ស ថែរក្សា ជួសជុលសមុច្ច័យ និងជំរុញធ្វើឱ្យមានភាពសម្បូរណ៍បែបនៃសមុច្ច័យសាធារណៈ
- សិក្សាស្រាវជ្រាវ ចងក្រងឯកសារ ចុះបញ្ជីសមុច្ច័យ រៀបចំកាតាឡុក និងតាំងពិព័រណ៍ ដើម្បីការអប់រំផ្សព្វផ្សាយដល់សាធារណៈ
- ពង្រឹងការអភិរក្សសមុច្ច័យ ដោយសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ក្នុងការជំរុញការអភិវឌ្ឍ និងការបង្កើនសារមន្ទីរ
- សហការ និងចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំ ដើម្បីគ្រប់គ្រងសមុច្ច័យ និងដំណើរការសារមន្ទីរ

- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

**មាត្រា២៩ .-**

នាយកដ្ឋានអភិរក្សសំណង់បេតិកភណ្ឌមានភារកិច្ចដូចខាងក្រោម៖

- ថែរក្សា ការពារ ជួសជុលសំណង់បេតិកភណ្ឌ និងគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយភាគីដែលពាក់ព័ន្ធ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ចុះបញ្ជីសារពើភណ្ឌ និងចាត់ថ្នាក់ជាសំណង់បេតិកភណ្ឌ និងរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌
- សិក្សាស្រាវជ្រាវ ចងក្រងឯកសារ និងផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីសំណង់បេតិកភណ្ឌ សំណង់ប្រវត្តិសាស្ត្រ និងរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌
- សហការរៀបចំឯកសារស្នើសុំចុះបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ក្នុងបញ្ជីបេតិកភណ្ឌថ្នាក់តំបន់ និងពិភពលោក របស់អង្គការយូណេស្កូឬស្ថាប័នអន្តរជាតិផ្សេងទៀត
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធក្នុងការទប់ស្កាត់ និងចាត់វិធានការលើបទល្មើសបំផ្លិចបំផ្លាញសំណង់បេតិកភណ្ឌ សំណង់ប្រវត្តិសាស្ត្រ និងរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌
- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

**មាត្រា៣០ .-**

នាយកដ្ឋានបុរាណវិទ្យាមានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ កំណត់ទីតាំង ចុះបញ្ជីសារពើភណ្ឌ និងធ្វើចំណាត់ថ្នាក់បុរាណស្ថាន ស្ថានីយបុរាណដែលនៅលើដី ក្រោមដី និងក្រោមទឹក
- ធ្វើកំណាយបុរាណវិទ្យាលើទីតាំងបុរាណដ្ឋាន និងទីតាំងផ្សេងទៀតដែលមានសារៈសំខាន់សម្រាប់ការយល់ដឹងពីសង្គម និងវប្បធម៌

- សហការនិងចូលរួមធ្វើផែនទី កំណត់ព្រំប្រទល់ និងបោះបង្គោលតំបន់ការពារបុរាណស្ថាន
- សហការនិងចូលរួមក្នុងការពិនិត្យ និងវាយតម្លៃរាល់គម្រោងអភិវឌ្ឍន៍ និងវិនិយោគនានាដែលមានផលប៉ះពាល់បុរាណស្ថាន ដើម្បីផ្តល់យោបល់ជូនស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- សិក្សាវិភាគ អភិរក្ស ជួសជុលសំណាកផ្សេងៗ ដែលបានពីកំណាយ
- ត្រួតពិនិត្យ ចុះបញ្ជីវត្ថុ និងសំណាកផ្សេងៗដែលបានពីកំណាយ មុននឹងអនុញ្ញាតឱ្យធ្វើការនាំចេញទៅវិភាគនៅក្រៅប្រទេស
- បោះពុម្ព ផ្សព្វផ្សាយសលាកបត្រព័ត៌មានបុរាណស្ថាន និងលទ្ធផលកំណាយបុរាណវិទ្យា
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធក្នុងការទប់ស្កាត់ និងចាត់វិធានការលើបទល្មើសបំផ្លិចបំផ្លាញបុរាណស្ថាន
- ធ្វើកំណាយបង្ការ ឬកំណាយសង្គ្រោះទីតាំង ឬតំបន់បេតិកភណ្ឌដែលជាគម្រោងអភិវឌ្ឍន៍ និងវិនិយោគនានា
- សហការជាមួយអង្គភាពផ្សេងទៀតក្នុងក្របខ័ណ្ឌក្រសួង ដើម្បីធានាអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់នាយកដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក។

## ជំពូកទី៧
## សាលាជាតិវិចិត្រសិល្បៈ

**មាត្រា៣១ .-**

សាលាជាតិវិចិត្រសិល្បៈជាគ្រឹះស្ថានសិក្សាមានភារកិច្ចដូចខាងក្រោម៖

- អប់រំ និងបណ្តុះបណ្តាលធនធានមនុស្សលើវិស័យសិល្បៈវប្បធម៌កម្រិតបឋមនិងកម្រិតមធ្យមសិក្សាបច្ចេកទេស
- រៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សាឱ្យសមស្របតាមស្តង់ដាជាតិសមត្ថភាព និងកម្រិតគុណវុឌ្ឍិជាតិ ដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចនិងតម្រូវការទីផ្សារការងារ
- រៀបចំយន្តការជ្រើសរើសសិស្សចូលរៀនមុខជំនាញសិល្បៈ តាមឧបនិស្ស័យ និងលើកទឹកចិត្តសិស្សឱ្យរៀនចប់សព្វគ្រប់នូវកម្មវិធីសិក្សា
- សិក្សាស្រាវជ្រាវ ចងក្រង និងតម្កល់ឯកសារវិធីសាស្ត្របង្រៀន និងឯកសារបច្ចេកទេសសិល្បៈ
- សម្របសម្រួល និងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអប់រំបច្ចេកទេស និងវិជ្ជាជីវៈសិល្បៈ

- សហការរៀបចំផែនការអភិវឌ្ឍសាលាជាតិ និងកសាងសមត្ថភាព ក៏ដូចជាធ្វើវិក្រឹត្យការមន្ត្រីរាជការ បុគ្គលិកជំនាញបច្ចេកទេស និងគ្រូបង្រៀន តាមសំណូមពរជាក់ស្តែង សម្រាប់បម្រើការបណ្តុះបណ្តាលប្រកបដោយគុណភាព
- សហការនិងសម្របសម្រួលជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំផែនការអភិវឌ្ឍ និងការកសាងសមត្ថភាពគ្រូបង្រៀន សម្រាប់កិច្ចដំណើរការសាលាវិចិត្រសិល្បៈភូមិភាគ
- កែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈរូបវន្តសម្រាប់បម្រើការបណ្តុះបណ្តាលបច្ចេកទេសសិល្បៈប្រកបដោយគុណភាពពិតប្រាកដ
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់សាលាក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់សាលាជាតិវិចិត្រសិល្បៈប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការទទួលបន្ទុក។

## ជំពូកទី៨

## អធិការដ្ឋាន

**មាត្រា៣២ .-**

អធិការដ្ឋានមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការនិងធ្វើអធិការកិច្ចស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សហការរៀបចំកសាងលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងនិយាមប្រតិបត្តិក្នុងវិស័យអធិការកិច្ច
- ទទួលនិងធ្វើអធិការកិច្ចតាមពាក្យបណ្តឹងតវ៉ានិងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងមជ្ឈដ្ឋានសាធារណៈពាក់ព័ន្ធនឹងវិស័យសិល្បៈវប្បធម៌តាមរយៈបណ្តឹងដោយផ្ទាល់ ប្រព័ន្ធសារព័ត៌មាន ប្រព័ន្ធបច្ចេកវិទ្យា បណ្តឹងអនាមិក និងគ្រប់មធ្យោបាយ
- ទទួលពិនិត្យ ស្រាវជ្រាវ និងដោះស្រាយបណ្តឹងតវ៉ា បណ្តឹងបរិហារ និងវិវាទក្នុងសមត្ថកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការ និងដោះស្រាយរាល់សកម្មភាពបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ និងសកម្មភាពធ្វើឱ្យប៉ះពាល់ដល់វប្បធម៌សិល្បៈ ទំនៀមទម្លាប់ ប្រពៃណីដ៏ថ្លៃថ្លារបស់ជាតិ
- ធ្វើអធិការកិច្ចលើជំនាញបច្ចេកទេសដោយផ្អែកលើអភិក្រម ហានិភ័យ និងករណីសង្ស័យចំពោះអង្គភាពក្រោមឱវាទក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងទីតាំងអាជីវកម្មពាក់ព័ន្ធនឹងវិស័យសិល្បៈវប្បធម៌តាមបណ្តារាជធានី ខេត្ត ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពអនុលោមតាមច្បាប់ស្របតាមនិយាមប្រតិបត្តិ
- ធ្វើអធិការកិច្ចតាមបញ្ជាឬការសម្រេចពីរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើប្រសិទ្ធភាពការអនុវត្តចំពោះកិច្ចសហប្រតិបត្តិការដែលបញ្ញត្តិក្នុងអនុស្សរណៈ ឬឯកសារពាក់ព័ន្ធផ្សេងទៀតរវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ព្រមទាំងសង្គមស៊ីវិល
- ចូលរួមសហការក្នុងដំណើការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសោធារណៈ
- តាមដានវិធានការដែលអធិការដ្ឋានបានដាក់ចេញ ដោយក្រើនរំលឹកដល់អង្គភាពរងអធិការកិច្ចចំពោះការដឹកនាំនិងគ្រប់គ្រង
- សិក្សា ស្រាវជ្រាវ ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ច
- ធ្វើរបាយការណ៍លទ្ធផលអធិការកិច្ចជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីពិនិត្យសម្រេចមុននឹងចម្លងជូនក្រសួងអធិការកិច្ច ស្របតាមលិខិតបទដ្ឋានគតិយុត្ត
- រៀបចំរបាយការណ៍លទ្ធផលអធិការកិច្ចប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងអធិការកិច្ច
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់អធិការដ្ឋានក្នុងក្របខ័ណ្ឌនៃការអនុវត្តភារកិច្ច
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការទទួលបន្ទុក។

## ជំពូកទី៩
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៣៣ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបានរៀបចំនិងទទួលបន្ទុកអនុវត្តតួនាទីនិងភារកិច្ចដែលបានកំណត់ក្នុងអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង អនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ និងអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១០
## អគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិយូណេស្កូកម្ពុជា

**មាត្រា៣៤ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិយូណេស្កូកម្ពុជា ដូចមានចែងក្នុងចំណុច២ នៃមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី១១
## គ្រឹះស្ថានសាធារណៈរដ្ឋបាល

**មាត្រា៣៥ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៤ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី១២
## អង្គភាពថ្នាក់ក្រោមជាតិ

**មាត្រា៣៦ .-**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានអង្គភាពថ្នាក់ក្រោមជាតិដែលជាមន្ទីរវប្បធម៌និងវិចិត្រសិល្បៈនៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីអនុវត្តភារកិច្ចនៅថ្នាក់ក្រោមជាតិ ដោយអនុលោមតាមមាត្រា២នៃអនុក្រឹត្យនេះ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមន្ទីរវប្បធម៌និងវិចិត្រសិល្បៈនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១៣
## ថវិកានិងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៣៧ .-**

ការរៀបចំនិងការអនុវត្តថវិការបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវអនុវត្តផ្អែកលើទំហំឥណទាន និងមុខសញ្ញាថវិកាដែលត្រូវបានអនុវត្តក្នុងច្បាប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិនិងហិរញ្ញវត្ថុរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន។

**មាត្រា៣៨ .-**

រាល់ឯកសារ ព័ត៌មាន និងទិន្នន័យដែលត្រូវបានរៀបចំ ប្រើប្រាស់ និងបម្រុងប្រើប្រាស់សម្រាប់អនុវត្តមុខងារនិងភារកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈគឺជាទ្រព្យសម្បត្តិសាធារណៈរបស់ក្រសួង។

ថ្នាក់ដឹកនាំនិងមន្ត្រីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវចាត់ចែង គ្រប់គ្រង និងរក្សាទុករាល់ឯកសារ ព័ត៌មាននិងទិន្នន័យនៅក្នុងអង្គភាព ដោយមិនត្រូវធ្វើឱ្យខូចខាត ឬធ្វើឱ្យបាត់បង់ ឬធ្វើឱ្យបែកធ្លាយទៅខាងក្រៅដោយប្រការណាមួយឡើយ និងត្រូវប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារនិងភារកិច្ចដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។

## ជំពូកទី១៤
## អន្តរប្បញ្ញត្តិ

**មាត្រា៣៩ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទក្រសួងនិងការតែងតាំងមន្ត្រីរាជការនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវបន្តមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មន្ត្រីរាជការស៊ីវិលនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលត្រូវបានប៉ះពាល់ដោយការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវរក្សាទុកអត្ថប្រយោជន៍ផ្នែកបៀវត្សយ៉ាងហោចក្នុងកម្រិតដដែល។

## ជំពូកទី១៥

## អវសានប្បញ្ញត្តិ

**មាត្រា៤០ ..**

អនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៤កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**



ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២៦
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**រូបសញ្ញារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ពិពណ៌នាអំពីរូបសញ្ញារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

១- ព្រះកេសព្រះបាទជ័យវរ្ម័នទី៧ ពណ៌ទឹកមាសស្រអាប់នៅចំកណ្តាលតំណាងឱ្យបញ្ញាញាណ ឧត្តមគតិភាពវៃឆ្លាត និងភាពទទួលខុសត្រូវក្នុងការដឹកនាំប្រទេសរបស់ថ្នាក់ដឹកនាំខ្មែរ

២- កម្រងផ្កាឈូកទ្រព្រះកេសព្រះបាទជ័យវរ្ម័នទី៧ ពណ៌ទឹកមាសថ្លា តំណាងឱ្យភាពល្អបរិសុទ្ធនៃព្រះពុទ្ធសាសនា រួមនិងការបង្កើតឡើងនូវលទ្ធិពុទ្ធរាជា ក្នុងការគ្រប់គ្រងប្រទេសរបស់វីរៈមហាក្សត្រខ្មែរ

៣- ផែនដីនៅពីក្រោមកម្រងផ្កាឈូករាងឆ្នូត៤ ត្រឹមពាក់កណ្តាល ខាងក្រោមមានស្នាមអង្កាញ់ជា ទឹករលកពណ៌ទឹកមាសស្រអាប់ តំណាងឱ្យភពផែនដី និងធាតុទាំង៤ គឺ ទឹក ដី ភ្លើង ខ្យល់ ដែលជាលោកធាតុផ្តល់នូវកំណើតមនុស្ស និងធម្មជាតិ

៤- ត្រីសូល៍ដែលនៅពីក្រោមជាប់នឹងផែនដីពណ៌ទឹកមាសស្រអាប់ផ្ទៃក្នុងថ្លា តំណាងឱ្យបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ និងតំណាងឱ្យព្រហ្មញ្ញសាសនា និងពុទ្ធសាសនាដែលស្ថិតនៅរួម ជាមួយគ្នាក្នុងជំនឿរបស់ប្រជាជនកម្ពុជា

៥- ក្បាច់ផ្កាដូងដែលមានរាងជារង្វង់អមសងខាងរូបព្រះកេសព្រះបាទជ័យវរ្ម័នទី៧ ពណ៌ទឹកមាសស្រអាប់ តំណាងឱ្យភោគផលកសិកម្មដ៏សម្បូរហូរហៀរ ដែលសបញ្ជាក់ឱ្យឃើញនូវភាពឧស្សាហ៍ព្យាយាមរបស់បុព្វបុរសខ្មែរដែលបានកសាងទឹកដីឱ្យសម្បូររុងរឿង

៦- ពណ៌ទឹកមាសខ្ចី និងស្រអាប់ គឺតំណាងឱ្យសញ្ញាសង្គ្រោះដល់វប្បធម៌ អារ្យធម៌ខ្មែរ និងប្រជាពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា

៧- ឈ្មោះក្រសួងវប្បធម៌និងវិចិត្រសិល្បៈនៅផ្ទៃខាងក្រោម ដោយមានពាក្យក្រសួងនៅចំកណ្តាល ផ្ទៃទី១ ហើយពាក្យវប្បធម៌ និងវិចិត្រសិល្បៈនៅផ្ទៃទី២ អមសងខាងសរសេរជាអក្សរព [illegible] តំណាងឱ្យបរិស្ថានធម្មជាតិដ៏ស្រស់បំព្រងនៃទឹកដីកម្ពុជា រួមនិងក្តីសង្ឃឹមលើសាមគ្គីភាពជាតិរបស់ប្រជាជនខ្មែរក្នុងការលើកស្ទួយវប្បធម៌ជាតិឱ្យរីកចម្រើនខ្ពង់ខ្ពស់ឡើងវិញ។

## ត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ



## ពិពណ៌នាអំពីត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

១. មានរង្វង់មូលខាងក្រៅពីរជាន់ មានអក្សរផ្នែកខាងលើ **"ព្រះរាជាណាចក្រកម្ពុជា"** ផ្នែកកណ្តាល **"រូបក្បាច់ផ្កាឆ្វេងស្តាំ"** និងផ្នែកខាងក្រោមឈ្មោះ **"ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ"** នៅចន្លោះរង្វង់មូលទី៣។

២. ផ្នែកខាងក្នុងរង្វង់មូលទី៣ ចំណុចកណ្តាលមានរូបប្រាសាទអង្គរវត្តតំណាងឱ្យបាវចនា **"ជាតិ សាសនា ព្រះមហាក្សត្រ"**។



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣៨៤៥ អនក្រ.តត

# អនុក្រឹត្យ
# ស្ដីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៨២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ២៨១ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-**

ត្រូវបានតែងតាំងលោក **ហែម រិទ្ធី** អត្តលេខ ១៧៩១២០០២៣១ ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធាននាយកដ្ឋានប្រតិបត្តិការ និងនីតិវិធី នៃអគ្គលេខាធិការដ្ឋាន មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន នៃទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៣៤៦ អនក្រ.តត**

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរភារកិច្ចនិងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ .—**

ត្រូវបានផ្ទេរភារកិច្ចលោក **ផៃ ម៉ុនវណ្ណៈ** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ២ ពីអភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ឱ្យមកបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ។

**មាត្រា២ .—**

ត្រូវបានតែងតាំងលោក **រិទ្ធី ប៉ាក់** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ឱ្យកាន់មុខតំណែងជាអភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ។

**មាត្រា៣ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៤៧ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពី**

**ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់លោក **ម៉ម ណារ៉េ** អត្តលេខ **១៥៧០៨០០៣៧៦** នៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ **១** នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី**១** ខែ**មីនា** ឆ្នាំ**២០២៦**។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៤៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ .–**

ត្រូវបានដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់លោក **នូ សុខា** អត្តលេខ **១៧១១២០០០៣៨** នៅក្នុងឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងបរិស្ថាន តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី**១** ខែ**វិច្ឆិកា** ឆ្នាំ**២០២៥**។

**មាត្រា២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១កើត ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣៤៩ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## **សម្រេច**

**មាត្រា១ .-**

ត្រូវបានដាក់ឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈដល់លោក **សាន លឹមអ៊ិន** អត្តលេខ **១៧៥០៣០០០៦៦** ឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ **១** នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១ កើត ខែ ពិសាខ ឆ្នាំ មមី អដ្ឋស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៥០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា១ .—**

ត្រូវបានដាក់ឱ្យចូលនិវត្តន៍នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១៣រូប ដូចមានរាយនាមខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | **ឆាង** | **សុផាត** | អត្តលេខ | ០១៦៧២ |
| ២- | វរសេនីយ៍ឯក | **ណាំ** | **ម៉ូលី** | អត្តលេខ | ០៤២៣៧ |
| ៣- | វរសេនីយ៍ឯក | **តិន** | **ឆន** | អត្តលេខ | ០៥៣៧៨ |
| ៤- | វរសេនីយ៍ឯក | **ចាន់** | **ឆោម** | អត្តលេខ | ០៥៦២៤ |
| ៥- | វរសេនីយ៍ឯក | **តាន់** | **ឆៃអ៊ីន** | អត្តលេខ | ០៦៣២៨ |
| ៦- | វរសេនីយ៍ឯក | **កេត** | **ជា** | អត្តលេខ | ០៧៥១៣ |
| ៧- | វរសេនីយ៍ឯក | **សេង** | **ស្វ** | អត្តលេខ | ០៧៨១០ |
| ៨- | វរសេនីយ៍ឯក | **លីម** | **សេងហ៊ីម** | អត្តលេខ | ០៨១៩២ |
| ៩- | វរសេនីយ៍ឯក | **ខៀម** | **វ៉ាត** | អត្តលេខ | ០៨២៦៨ |
| ១០- | វរសេនីយ៍ឯក | **សំ** | **សុខា** | អត្តលេខ | ០៩៤៩៩ |
| ១១- | វរសេនីយ៍ឯក | **ឃុល** | **តិន** | អត្តលេខ | ១៩០៧៧ |
| ១២- | វរសេនីយ៍ឯក | **ប៉ាង** | **ហៀង** | អត្តលេខ | ២១៩៤៨ |
| ១៣- | វរសេនីយ៍ឯក | **អ៊ុំ** | **សុខមនោ** | អត្តលេខ | ៣៧១៥៦។ |

**មាត្រា២ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៩១ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយការងារ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីស្ម័គ្រចិត្តនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំនួន ២៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **ប្រាក់ការងារ**

លោក សេង សំបាន អនុប្រធាននាយកដ្ឋាន។

ខ-មេដាយ **សំរិទ្ធការងារ**

១- លោកស្រី ហុង ស៊ាងហ៊ី មន្ត្រី
២- លោកស្រី ធីម ស្រីរី មន្ត្រី

| | | | |
|---|---|---|---|
| ៣- | លោកស្រី | ងួនរតនៈ សុជាតា | មន្ត្រី |
| ៤- | លោកស្រី | ឈៀ សុជាតា | មន្ត្រី |
| ៥- | លោកស្រី | នៃ ច័ន្ទវិសាល | មន្ត្រី |
| ៦- | លោកស្រី | ឡាំ ម៉ីលីញ | មន្ត្រី |
| ៧- | លោកស្រី | ឡាំ ម៉ីលី | មន្ត្រី |
| ៨- | លោក | សោ សិរីពន្លឺ | មន្ត្រី |
| ៩- | លោក | សូ សុភា | មន្ត្រី |
| ១០- | លោក | រឹម សុខសុភ័ក្ត្រ | មន្ត្រី |
| ១១- | លោកស្រី | គួយ ហង្សលីនណា | មន្ត្រី |
| ១២- | លោក | សេក ឧត្តម | មន្ត្រី |
| ១៣- | លោក | យ៉ាត សំណាង | មន្ត្រី |
| ១៤- | លោកស្រី | ឡេញ ដាណេ | មន្ត្រី |
| ១៥- | លោកស្រី | ថោង សុផាតារាវត្តី | មន្ត្រី |
| ១៦- | លោកស្រី | សុខ កែវរស្មី | មន្ត្រី |
| ១៧- | លោកស្រី | ហួន ពៅ | មន្ត្រី |
| ១៨- | លោក | ជា បុញ្ញនិធិ | មន្ត្រី |
| ១៩- | លោកស្រី | ជា លីស៊ាន | មន្ត្រី |
| ២០- | លោក | ថន ជារ៉ា | មន្ត្រីជាប់កិច្ចសន្យា |
| ២១- | លោកស្រី | រី កែវ | មន្ត្រីស្ម័គ្រចិត្ត |
| ២២- | លោកស្រី | ផន ស្រីលាភ | មន្ត្រីស្ម័គ្រចិត្ត |
| ២៣- | លោក | ប្រុក ប៉ាវ | ជំនួយការរដ្ឋបាល |
| ២៤- | លោកស្រី | ម៉ន ស្រីលាភ | មន្ត្រីស្ម័គ្រចិត្ត។ |

**មាត្រា២**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣៩២...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីអប់រំ ចំនួន ៤៦រូប នៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តមណ្ឌលគិរី ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | |
|---|---|---|
| ១-លោកស្រី | តី ឃឹម | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ២-លោក | កូ គឿន | ប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៣-លោក | អ៊ីប ហឿន | អនុប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៤-លោក | យាង សារ៉ុម | អនុប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៥-លោកស្រី | ប្រៃ ជូ | អនុប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |

| | | |
|---|---|---|
| ៦- លោក | នាង ឆវី | អនុប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៧- លោក | ទូច ស៊ីនឿន | អនុប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៨- លោក | យ៉ា ចន្ថន | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៩- លោក | អែម ចាន់ដារ៉ា | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន មណ្ឌលគិរី ក្រុងសែនមនោរម្យ |
| ១០- លោក | អ៊ិន អែល | នាយកវិទ្យាល័យ ហ៊ុន សែន កែវសីមា ស្រុកកែវសីមា |
| ១១- លោក | យ៉ាំ សេងហ៊ាង | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កោះញែក ស្រុកកោះញែក |
| ១២- លោក | ជូ ច័ន្ទសារៈ | នាយករងអនុវិទ្យាល័យសុខសាន្ត ស្រុកកោះញែក។ |

ខ-មេដាយ **ប្រាក់ការងារ**

| | | |
|---|---|---|
| ១- លោក | ជឿន ខេន | អនុប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ២- លោក | ម៉ៅ ផល្លី | អនុប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៣- លោក | ផន ចាន់ថន | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៤- លោក | ភាព សុផាត | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៥- លោកស្រី | ហ៊ិត សុភានិត | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី |
| ៦- លោក | ទើម ពេជ្រលី | នាយកវិទ្យាល័យមេម៉ង់ ស្រុកកែវសីមា |
| ៧- លោក | លី សំណាង | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន មណ្ឌលគិរី ក្រុងសែនមនោរម្យ |
| ៨- លោកស្រី | មោក រស្មី | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន មណ្ឌលគិរី ក្រុងសែនមនោរម្យ |
| ៩- លោកស្រី | យី ស្រីខួច | គ្រូបង្រៀនអនុវិទ្យាល័យមនោរម្យ ក្រុងសែនមនោរម្យ |
| ១០- លោក | រុន សុភ័ក្រ្ត | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កោះញែក ស្រុកកោះញែក |
| ១១- លោកស្រី | ចេវ ស្រីប៉ាង | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កោះញែក ស្រុកកោះញែក។ |

គ-មេដាយ **សំរឹទ្ធការងារ**

| | | |
|---|---|---|
| ១- លោកស្រី | មិន ដារ័ត្ន | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន មណ្ឌលគិរី ក្រុងសែនមនោរម្យ |
| ២- លោកស្រី | ជី ចន្នី | គ្រូបង្រៀនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមណ្ឌលគិរី ក្រុងសែនមនោរម្យ |
| ៣- លោកស្រី | អាន មុន្នីរ័ត្ន | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន មណ្ឌលគិរី ក្រុងសែនមនោរម្យ |
| ៤- លោក | ផាន់ តុលា | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន មណ្ឌលគិរី ក្រុងសែនមនោរម្យ |
| ៥- លោក | ង៉ែត ផល្លា | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កែវសីមា ស្រុកកែវសីមា |
| ៦- លោក | ម៉ា សុផាន់ណេត | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កែវសីមា ស្រុកកែវសីមា |
| ៧- លោកស្រី | ផៃ ស្រីពេជ្យ | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កែវសីមា ស្រុកកែវសីមា |
| ៨- លោកស្រី | ពុំ ស្រីនិច | គ្រូបង្រៀនវិទ្យាល័យមេម៉ង់ ស្រុកកែវសីមា |
| ៩- លោកស្រី | ជុំ ជាចរិយា | គ្រូបង្រៀនអនុវិទ្យាល័យស្រែព្រះ ស្រុកកែវសីមា |
| ១០- លោកស្រី | ចែន ចាន់ថេង | គ្រូបង្រៀនអនុវិទ្យាល័យឆ្វេង ស្រុកកែវសីមា |
| ១១- លោកស្រី | កក សុគា | គ្រូបង្រៀនអនុវិទ្យាល័យស្រែឈូក ស្រុកកែវសីមា |
| ១២- លោកស្រី | រ័ត្ន សុមុនា | គ្រូបង្រៀនវិទ្យាល័យជ្រោះប៊ូស្រា ស្រុកពេជ្រាដា |
| ១៣- លោកស្រី | ព្រំ កន្និកា | គ្រូបង្រៀនវិទ្យាល័យជ្រោះប៊ូស្រា ស្រុកពេជ្រាដា |



៩

១៤- លោក ចាន់ សម្បត្តិ គ្រូបង្រៀនវិទ្យាល័យជ្រោះប៊ូស្រា ស្រុកពេជ្រាដា
១៥- លោកស្រី វ៉េត វណ្ណា គ្រូបង្រៀនអនុវិទ្យាល័យទួលព្រីង ស្រុកពេជ្រាដា
១៦- លោក ធឿន សុខថុន គ្រូបង្រៀនអនុវិទ្យាល័យអូរប្លាយ ស្រុកពេជ្រាដា
១៧- លោកស្រី អ៊ុន ច័ន្ទតារាត្តី គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កោះញែក ស្រុកកោះញែក
១៨- លោកស្រី ហ៊ន សុខហេង គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កោះញែក ស្រុកកោះញែក
១៩- លោកស្រី ខេង ជីវ៉ា គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន កោះញែក ស្រុកកោះញែក
២០- លោក ឈុន ផានេត គ្រូបង្រៀនអនុវិទ្យាល័យសុខសាន្ត ស្រុកកោះញែក
២១- លោក ស៊ិន សុភ័ក្រ គ្រូបង្រៀនវិទ្យាល័យអូររាំង ស្រុកអូររាំង
២២- លោក តេង សុវណ្ណារិទ្ធ គ្រូបង្រៀនវិទ្យាល័យអូររាំង ស្រុកអូររាំង
២៣- លោកស្រី ផុន ស្រីយ៉ែន គ្រូបង្រៀនអនុវិទ្យាល័យដាក់ដាំ ស្រុកអូររាំង។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៤កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥០ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការចាត់តាំងបន្ថែមអនុប្រធាន ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២០៩ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- បានឃើញសេចក្ដីណែនាំរបស់រាជរដ្ឋាភិបាលលេខ០៤ សណន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ .–**

ត្រូវបានចាត់តាំង ឯកឧត្តម **រិន ធីរះ** រដ្ឋលេខាធិការក្រសួងផែនការ ជាអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ។

**ប្រការ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ និងរដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៦កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៦៨១.....សហវ.ក.ហក.ទសក

**ប្រកាស**
**ស្តីពី**
**វិធាន និងនីតិវិធីនៃការគ្រប់គ្រងគណនីរបស់និត្យ្តករគេនាគារ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៨៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

**សម្រេច**

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងគណនីរបស់និក្ខិត្តករតនាគារ ឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះនីតិបុគ្គលសាធារណៈនីតិបុគ្គលឯកជន និងរូបវន្តបុគ្គល ដែលបើកគណនីនៅរតនាគារកណ្តាល ឬរតនាគាររាជធានី ខេត្ត ដើម្បីរក្សាទុកសាច់ប្រាក់ ជាកាតព្វកិច្ច ឬដោយស្ម័គ្រចិត្ត។

## ជំពូកទី២
## គោលការណ៍ទូទៅនៃការគ្រប់គ្រងគណនីរបស់និក្ខិត្តកររតនាគារ

### ផ្នែកទី១
### គោលការណ៍ទូទៅ

**ប្រការ៣.-**

ការគ្រប់គ្រងគណនីរបស់និក្ខិត្តកររតនាគារត្រូវគោរពតាមគោលការណ៍ ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ប្រការ៤.-**

ការគ្រប់គ្រងគណនីរបស់និក្ខិត្តកររតនាគារត្រូវធានាបានប្រសិទ្ធភាពតាមរយៈ៖

-ត្រៀមលក្ខណៈបានទាន់ពេលសម្រាប់ការគ្រប់គ្រងរាល់ប្រតិបត្តិការ

-ធ្វើពិពិធកម្មនៃវិធីទូទាត់ប្រាក់តាមតម្រូវការរបស់និក្ខិត្តកររតនាគារ

-ធ្វើទំនើបកម្មនៃវិធីទូទាត់ ដើម្បីផ្តល់ជូននិក្ខិត្តកររតនាគារ

-កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ ក្នុងករណីពុំចាំបាច់។

**ប្រការ៥.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវបើកគណនីនៅរតនាគារសម្រាប់ការគ្រប់គ្រងថវិការបស់ខ្លួន លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

u

## ផ្នែកទី២
## សិទ្ធិអំណាច និងការទទួលខុសត្រូវ

**ប្រការ៦.-**

និក្ខិត្តករតេនាគារ សំដៅដល់នីតិបុគ្គលសាធារណៈ ឬនីតិបុគ្គលឯកជន ឬរូបវន្តបុគ្គល ដែលផ្ញើមូលនិធិនៅតេនាគារ ជាកាតព្វកិច្ច ឬដោយស្ម័គ្រចិត្ត។

នីតិបុគ្គលសាធារណៈ រួមមាន៖ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីថវិកាជាតិ។

គណនីរបស់និក្ខិត្តករតេនាគារ គឺជាគណនីប្រាក់បញ្ញើរបស់នីតិបុគ្គលសាធារណៈ ឬនីតិបុគ្គលឯកជន ឬរូបវន្តបុគ្គលដែលបើកជាមួយតេនាគារកណ្តាល ឬតេនាគាររាជធានី ខេត្ត ពាក់ព័ន្ធ ។

**ប្រការ៧.-**

និក្ខិត្តករតេនាគារ មានសិទ្ធិ និងមានការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងចាត់ចែងមូលនិធិនៅក្នុងគណនីរបស់ខ្លួនដែលបានបើកនៅតេនាគារ។ និក្ខិត្តករតេនាគារ អនុញ្ញាតឱ្យធ្វើប្រតិបត្តិការចំណូល ចំណាយតាមរយៈគណនេយ្យករតេនាគារ។

គណនេយ្យករតេនាគារទទួលបន្ទុកគ្រប់គ្រងគណនីរបស់និក្ខិត្តករតេនាគារ។

**ប្រការ៨.-**

គណនីប្រាក់បញ្ញើរបស់និក្ខិត្តករ មិនត្រូវមានវិបារូបន៍។

## ជំពូកទី៣
## នីតិវិធីនៃការបើកគណនី ប្រតិបត្តិការ និងបិទគណនី
## ផ្នែកទី១
## នីតិវិធីនៃការបើកគណនី

**ប្រការ៩.-**

និក្ខិត្តករតេនាគារអាចបើកគណនីតែមួយគត់នៅតេនាគារ លើកលែងតែមានគោលការណ៍អនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១០.-**

សំណុំលិខិតយុត្តិការសំខាន់ៗ សម្រាប់ការស្នើសុំបើកគណនីនៅតេនាគារ មានជាអាទិ៍៖

-លិខិតស្នើសុំបើកគណនី (ឧបសម្ព័ន្ធទី១)

-គំរូហត្ថលេខា (ឧបសម្ព័ន្ធទី២)

-លិខិតគតិយុត្តដែលអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅតេនាគារ

-លិខិតគតិយុត្តតែងតាំងម្ចាស់គណនី និងអ្នកមានសិទ្ធ

-ឯកសារបញ្ជាក់អត្តសញ្ញាណជាច្បាប់ថតចម្លងដែលមានសុពលភាពរបស់ម្ចាស់គណនី និងអ្នកមានសិទ្ធិ

-ឯកសារផ្សេងៗតាមតម្រូវការ។

## ផ្នែកទី២
## នីតិវិធីនៃប្រតិបត្តិការគណនី

**ប្រការ១១._**

រាល់ការដកប្រាក់ពីគណនីរបស់និក្ខិត្តករតនាគារ ម្ចាស់គណនីត្រូវបំពេញសំណើរសុំដកប្រាក់ រួចបញ្ជូនមកគណនេយ្យកររតនាគារ។

គណនេយ្យកររតនាគារ ត្រូវពិនិត្យភាពត្រឹមត្រូវនៃសំណើរសុំដកប្រាក់ និងសមតុល្យនៃគណនីរបស់និក្ខិត្តកររតនាគារ មុននឹងធ្វើការដកប្រាក់តាមសំណើររបស់ម្ចាស់គណនី។

**ប្រការ១២._**

ការធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមការស្នើសុំរបស់និក្ខិត្តកររតនាគារ ពីគណនីមួយទៅគណនីមួយនៅរតនាគារ ត្រូវបានគិតកម្រៃរតនាគារ។ គណនេយ្យកររតនាគារត្រូវធ្វើការកាត់ចេញពីគណនីរបស់និក្ខិត្តកររតនាគារដោយស្វ័យប្រវត្តិដូចមានចែងនៅក្នុងប្រការ២០ និង២១ នៃប្រកាសនេះ។

**ប្រការ១៣._**

គណនេយ្យកររតនាគារនឹងផ្តល់ជូននិក្ខិត្តកររតនាគារនូវ ឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការចំណូល ប្រតិបត្តិការចំណាយ ក្នុងគណនីនិក្ខិត្តកររតនាគារ។

## ផ្នែកទី៣
## នីតិវិធីនៃការបិទគណនី

**ប្រការ១៤._**

គណនីរបស់និក្ខិត្តកររតនាគារត្រូវបានបិទក្នុងករណីណាមួយដូចខាងក្រោម៖

-មានលិខិតស្នើសុំបិទគណនីជាលាយលក្ខណ៍អក្សរពីនិក្ខិត្តកររតនាគារ

-គ្មានសកម្មភាពប្រតិបត្តិការរយៈពេល៣ឆ្នាំជាប់គ្នា

-ម្ចាស់គណនី បានប្រព្រឹត្តបទល្មើសសម្អាតប្រាក់ ឬមានជាប់ពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសផ្សេងៗ

- ការក្លែងបន្លំលិខិតយុត្តិការ

-ម្ចាស់គណនីមិនអនុវត្តតាមលក្ខខណ្ឌ ឬបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ១៥._**

គណនីរបស់និក្ខិត្តកររតនាគារដែលពុំមានសកម្មភាពប្រតិបត្តិការរយៈពេល៣ឆ្នាំជាប់គ្នា គណនេយ្យកររតនាគារត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅនិក្ខិត្តកររតនាគារស្តីពីការបិទគណនី។ ក្រោយពីការចេញលិខិតជូនដំណឹងរយៈពេល៤៥ថ្ងៃ នៃថ្ងៃធ្វើការ ពុំទទួលបានការឆ្លើយតបពីនិក្ខិត្តកររតនាគារ គណនេយ្យកររតនាគារនឹងធ្វើការបិទគណនីដោយស្វ័យប្រវត្តិ។

ﾚ

**ប្រការ១៦._**

ការបិទគណនីរបស់និក្ខិត្តករវតនាគារដែលនៅមានសមតុល្យ ក្នុងករណីដែលគណនីរបស់និក្ខិត្តករវតនាគារពុំមានសកម្មភាពរយៈពេល៣ឆ្នាំជាប់គ្នា ឬម្ចាស់គណនីបានប្រព្រឹត្តបទល្មើសសម្អាតប្រាក់ ឬមានជាប់ពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្ម ឬមានការក្លែងបន្លំលិខិតយុត្តិការ ឬបទល្មើសផ្សេងៗ ឬម្ចាស់គណនីពុំអនុវត្តតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន គណនេយ្យករវតនាគារមានសិទ្ធិផ្ទេរសមតុល្យដែលនៅសល់នោះចូលជាចំណូលថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១៧._**

ការបង្កក ឬឃាត់ទុកប្រាក់ដោយគណនេយ្យករវតនាគារ ក្នុងគណនីរបស់និក្ខិត្តករវតនាគារជាបណ្ដោះអាសន្ន អាចធ្វើទៅបានក្នុងករណីនិក្ខិត្តករវតនាគារត្រូវបានសង្ស័យថា មិនបានអនុវត្តទៅតាមគោលការណ៍ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ឬមានជាប់ពាក់ព័ន្ធនឹងបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយបុគ្គល ឬអង្គភាពដែលត្រូវបានហាមឃាត់ ឬជាប្រយោជន៍បំរើដល់សកម្មភាពល្មើសច្បាប់ ដោយទទួលបានគោលការណ៍ណែនាំ ឬទទួលបានព័ត៌មានពីអាជ្ញាធរពាក់ព័ន្ធ។

## ជំពូកទី៤
## ប្រភេទគណនី និងសេវាដែលផ្ដល់ដោយគណនេយ្យករវតនាគារ

**ប្រការ១៨._**

ប្រភេទគណនីប្រាក់បញ្ញើរបស់និក្ខិត្តករវតនាគារ រួមមានគណនីរបស់រដ្ឋទេយ្យករបុរេប្រទាន គណនីរបស់រដ្ឋទេយ្យករចំណូល គណនីមូលនិធិ គណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គណនីប្រាក់បញ្ញើរបស់អង្គភាពចំណុះក្រសួង គណនីប្រាក់បញ្ញើរបស់អង្គភាពសាធារណៈប្រហាក់ប្រហែល គណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គណនីប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ គណនីប្រាក់បញ្ញើរបស់ក្រុមហ៊ុនឯកជន និងគណនីប្រាក់បញ្ញើផ្សេងៗ។

**ប្រការ១៩._**

និក្ខិត្តករវតនាគារ អាចប្រើប្រាស់សេវាទូទាត់ទៅតាមតម្រូវការជូនអត្ថគាហកដែលមានគណនីនៅធនាគារដៃគូនានារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅទូទាំងប្រទេស។

**ប្រការ២០._**

និក្ខិត្តករវតនាគារ អាចប្រើប្រាស់សេវាបង្វែរប្រាក់ពីគណនីមួយទៅគណនីមួយទៀត នៅផ្ទៃក្នុងវតនាគារបានឆាប់រហ័សសម្រាប់ការទូទាត់សេវានានាទៅតាមតម្រូវការ ដោយបានកំណត់សេវាក្នុងអត្រា០.០២៥% នៃចំនួនទឹកប្រាក់ដែលត្រូវបង្វែរ។

**ប្រការ២១._**

និក្ខិត្តករវតនាគារ អាចប្រើប្រាស់សេវាបង្វែរប្រាក់រវាងវតនាគារកណ្ដាល និងវតនាគាររាជធានី ខេត្តទៅតាមតម្រូវការ ដោយបានកំណត់សេវាក្នុងអត្រា ០.០៤% នៃចំនួនទឹកប្រាក់ដែលត្រូវបង្វែរ។

ⷣ

**ប្រការ២២._**

និក្ខិត្តករតនាគារ អាចប្រើប្រាស់សេវាផ្ទេរប្រាក់ទៅក្រៅប្រទេស សម្រាប់បង់វិភាគទាន ឬសេវានានាទៅតាមតម្រូវការ ដោយបានកំណត់សេវាក្នុងអត្រា ០.០៤% នៃទឹកប្រាក់ដែលត្រូវផ្ទេរ។

## ជំពូកទី៥
## ការគ្រប់គ្រងគណនីប្រាក់បញ្ញើរបស់និក្ខិត្តករតនាគារ

**ប្រការ២៣._**

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវគ្រប់គ្រង និងអាចប្រើប្រាស់ប្រាក់ទំនេរនៃគណនីប្រាក់បញ្ញើរបស់និក្ខិត្តករតនាគារប្រកបដោយប្រសិទ្ធភាព ដើម្បីអាចផ្តល់ជាធនធានហិរញ្ញប្បទានដល់បន្ទុកថវិការដ្ឋ។

**ប្រការ២៤._**

គណនេយ្យកររតនាគារ ត្រូវកត់ត្រានូវរាល់ប្រតិបត្តិការចំណូល ចំណាយទាំងអស់ នៃគណនីនិក្ខិត្តករតនាគារ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដែលគាំទ្រដោយសក្ខីបត្រផ្សេងៗតាមតម្រូវការ។

គណនេយ្យកររតនាគារ ត្រូវធានាសុវត្ថិភាព ក្នុងការរក្សាទុកដាក់មូលនិធិរបស់និក្ខិត្តកររតនាគារ ពីការបាត់បង់ លើកលែងតែករណីប្រធានសក្តិកើតឡើង។

**ប្រការ២៥._**

កម្រៃរតនាគារដែលបានមកពីការគ្រប់គ្រងគណនីរបស់និក្ខិត្តកររតនាគារ ត្រូវបានបែងចែកដូចខាងក្រោម៖

-៨០% ត្រូវបានរក្សាទុកជាកម្រៃអត្ថប្រយោជន៍រតនាគារ

-២០% ត្រូវបង្វែរចូលជាចំណូលថវិការដ្ឋ ។

## ជំពូកទី៦
## កិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍

**ប្រការ២៦._**

កិច្ចបញ្ជិកាគណនេយ្យ នៃប្រតិបត្តិការគ្រប់គ្រងគណនីប្រាក់បញ្ញើរបស់និក្ខិត្តកររតនាគារ ត្រូវកំណត់ដោយសារាចររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២៧._**

និក្ខិត្តកររតនាគារ ត្រូវរៀបចំស្ថានភាពចំណូល ចំណាយ ប្រចាំខែ ដើម្បីស្នើសុំធ្វើការផ្ទៀងផ្ទាត់ជាមួយគណនេយ្យកររតនាគារ។

របាយការណ៍ស្តីពីស្ថានភាពគណនីរបស់និក្ខិត្តកររតនាគារប្រចាំខែ និងប្រចាំឆ្នាំ ត្រូវផលិតចេញពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)។ គំរូរបាយការណ៍ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

ꟷ

**ប្រការ២៨.-**

រតនាគារកណ្តាល និងរតនាគាររាជធានី ខេត្ត ត្រូវផ្តល់ព័ត៌មានដែលពាក់ព័ន្ធ ប្រតិបត្តិការនៃគណនី និក្ខិត្តករតនាគារ ជាឯកសាររឹង ឬ តាមប្រព័ន្ធឌីជីថល ជូនដល់និក្ខិត្តករតនាគារដើម្បីជាមូលដ្ឋានចុះបញ្ជីតាមដាន ក្នុងការគ្រប់គ្រងគណនីរបស់ខ្លួន។

## ជំពូកទី៧
## ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**ប្រការ២៩.-**

កិច្ចប្រតិបត្តិការចំណូល ចំណាយ នៃគណនីប្រាក់បញ្ញើ ត្រូវអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃផ្សេងទៀត ដែលកំណត់ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ៣០.-**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ថ្ងៃ កើត ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣០*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ......សហវ.ប្រក.

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការតែងតាំងគ្នាក់ងារបើកផ្តល់ និងគ្នាក់ងារបើកផ្តល់ជំនួស ប្រចាំនៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងថវិកាគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យជាស៊ីមកំចាយមារ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ. បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការប្តូរឈ្មោះ"សាកលវិទ្យាល័យជាស៊ីមកំចាយមារ" មកជា "សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ"
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុ ជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ៧៧៧ សហវ.ប្រក.អថ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២២៤ ស្ដីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ៩២៩ សហវ.ប្រក.អថ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- បានឃើញប្រកាសលេខ៨៥២ សហវ.ប្រក.អថ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- បានឃើញបទបញ្ជាលេខ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា។

## សម្រេច

**ប្រការ១ ._**

ត្រូវបានតែងតាំង ភ្នាក់ងារបើកផ្ដល់ និងភ្នាក់ងារបើកផ្ដល់ជំនួស ប្រចាំនៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា ៖

| | |
|---|---|
| ១. លោកស្រី **នឿន វ៉ានកេស** | មុខងារជាមន្ត្រីការិយាល័យផែនការ និងហិរញ្ញកិច្ចភ្នាក់ងារបើកផ្ដល់ នៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ |
| ២. លោក **អ៊ឹម ប្រាក់** | មុខងារជាអនុប្រធានការិយាល័យផែនការ និងហិរញ្ញកិច្ចជាភ្នាក់ងារបើកផ្ដល់ជំនួស នៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ |

**ប្រការ២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

៣/៤

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣០......សហវ.ប្រក.[illegible]

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការតែងតាំងរដ្ឋលេខាធិការបុរេប្រទាន ប្រចាំនៅអង្គភាពថវិកាសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា

| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
|---|---|

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងថវិកាគណនេយ្យនិងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យជាស៊ីមកំចាយមារ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ. បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការប្តូរឈ្មោះ"សាកលវិទ្យាល័យជាស៊ីមកំចាយមារ" មកជា "សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ"
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុ ជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៦២ អយក.ប្រក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា

- បានឃើញប្រកាសលេខ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា។

**សម្រេច**

**ប្រការ១ ._**

ត្រូវបានតែងតាំងមន្ត្រីរាជការ **នៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ** នៃក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

| | |
|---|---|
| ១.លោក **ផន រ៉ុន** | មុខងារជាអនុប្រធានការិយាល័យផែនការ និងហិរញ្ញកិច្ច ជារជ្ជទេយ្យករបុរេប្រទាន នៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា |
| ២.លោកស្រី **ឡើន សុទ្ធិ** | មុខងារជានាយិកាប្រតិបត្តិរងសាខា **សជជក** ខេត្តកំពង់ចាម ជារជ្ជទេយ្យករបុរេប្រទានរង នៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា |
| ៣.លោក **ឡើន ម៉ាន់ឡែន** | មុខងារជានាយកប្រតិបត្តិរងសាខា **សជជក** ខេត្តព្រៃវែង ជារជ្ជទេយ្យករបុរេប្រទានរង នៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា។ |

**ប្រការ២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០២៦

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ឧបនាយករដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** |
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** |

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ ០៥៣ ឧវសន ... ... ប្រក

ថ្ងៃ ពុធ ១០ កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២៦

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ២០១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុងកំពង់សោម នៃខេត្តព្រះសីហនុ
- យោងលិខិតលេខ១៦៥៦/២០ ស.ត.ស.ព ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការវិនិយោគបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងផលិតម៉ាស់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ៨៩២/២៤ ស.ត.ស.ព ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការប្តូរអភិបាល របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ របស់ក្រុមហ៊ុន ហ៊ីង លី (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ហ៊ីង លី (ខេមបូឌា) ឯ.ក (HING LEE (CAMBODIA) CO., LTD.)** តំណាងដោយលោកស្រី **LYU, LI** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EJ6597166** ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងម៉ាស់ ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ (អគារលេខ៤ ភូមិពូធឿង សង្កាត់បិតត្រាំង និងភូមិស្មាច់ដែង សង្កាត់រាម ក្រុងកំពង់សោម ខេត្តព្រះសីហនុ) ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ១- សម្លៀកបំពាក់ (កាត់ដេរ) និងសម្លៀកបំពាក់ពេទ្យ | ១៤១០ |
| ២- ម៉ាស់ | ១៣៩៩ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងម៉ាស់ ហ៊ីង លី (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្ដល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៣២៤ ឧវបន.កឧ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ និងលិខិតលេខ១១៣ ឧវបន.កឧ.លស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៦ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូន៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- សាលាខេត្តព្រះសីហនុ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ
- រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

បណ្ឌិត ទឹម ស៊ីនី

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី